N°: 9 ... 29-5-53

INDOCHINE FRANÇAISE
DÉPOT LÉGAL

ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

"Kosseakneavaddey"

# កសិក្សានាវឌ្ឍី

សម្រាប់

# គ្រូបង្រៀន

ឆ្នាំទី ៤ លេខ ៩

ខែមិថុនា-កក្កដា ព.ស. ២៤៩៥

Juin - Juillet

ឆ្នាំសិក្សា ១៩៥២-១៩៥៣

# ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្តីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្តី សម្រាប់គ្រូបង្រៀន

បញ្ជីរឿង ទំព័រ


សេចក្តីណែនាំ ... ... ... ... ... ... ... ... ... ... ... ៣

ចតុត្ថដ្ឋាន មធ្យមដ្ឋានទី ២ ភាសា ... ... ... ... ... ... ... ៩

មធ្យមដ្ឋានទី ១ ភាសា ... ... ... ... ... ... ... ... ២០

អាទិកដ្ឋាន ភាសា ... ... ... ... ... ... ... ... ២៥

កុមារដ្ឋាន ភាសា ... ... ... ... ... ... ... ... ៤៣

បរិវច្ចណដ្ឋាន ភាសា ... ... ... ... ... ... ... ... ៤៦

តែងសេចក្តីសម្រាប់ប្រថមភូមិបំពេញវិជ្ជា ... ... ... ... ... ៤៩

តែងសេចក្តីសម្រាប់ប្រថមភូមិជាន់ដំបូង ... ... ... ... ... ៥៩

អាទិកដ្ឋាន នព្វន្ត - វង្វាស់ - វង្វាល់ ... ... ... ... ... ៦២

កុមារដ្ឋាន នព្វន្ត - វង្វាស់ - វង្វាល់ ... ... ... ... ... ៦៦

បរិវច្ចណដ្ឋាន នព្វន្ត - វង្វាស់ - វង្វាល់ ... ... ... ... ... ៦៧

អាទិកដ្ឋាន វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ... ... ... ... ៨១

បរិវច្ចណដ្ឋាន - វត្ថុស្វាធ្យាយន៍-វិធីបង្ការរោគ ... ... ... ... ៨៣

កុមារដ្ឋាន វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ... ... ... ... ៨៤

លោកនីតិ ... ... ... ... ... ... ... ... ... ... ... ... ៨៥

មេសូត្រតែមាត់ សម្រាប់គ្រប់ថ្នាក់ ... ... ... ... ... ... ៩០

CENTRE ROYAL DE DOCUMENTATION & D'EDITION
BIBLIOTHEQUE
Inventaire | Date 8-8-63
CDU | Côte

# សេចក្ដីណែនាំ

## អំពីបង្រៀនមុខវត្ថុស្វាធ្យាយន៍

ប្រយោជន៍.— ការបង្រៀនវត្ថុស្វាធ្យាយន៍មានប្រយោជន៍ធំណាស់ នឹងនាំឲ្យសិស្សចេះមើល ចេះសង្កេត ចេះពិចារណា ដោយបានឃើញរូបវត្ថុ ឃើញហេតុបណ្ដាលឡើងដូច្នេះដូច្នោះមែនៗ ៗ ក្នុងការបង្រៀននេះ ត្រូវទម្លាប់សិស្សឲ្យប្រើប្រដាប់វិញ្ញាណទាំងប្រាំ គឺប្រើឲ្យមើល ឲ្យពាល់ ឲ្យកាន់ ឲ្យលើកថ្លឹងទម្ងន់ ហិតក្លិន ស្ដាប់សូរ ភ្លក់ជាតិវត្ថុ ដែលយកមកបង្រៀននោះ យូរទៅក្មេងនឹងបានទៅជាឆ្លាតពូកែខាងមើល ត្រចៀកទៅជាវៃប្រសប់ខាងស្ដាប់សូរ ច្រមុះប្រសប់ខាងហិតក្លិន-អណ្ដាតប្រសប់ខាងសំគាល់រសជាតិ ដៃប្រសប់ខាងដឹងការដោយប៉ះពាល់ ៗ

របៀបបង្រៀន.— ការបង្រៀនវត្ថុស្វាធ្យាយន៍ គឺ បង្រៀនចំពោះវត្ថុអ្វីមួយដូចជាបន្ទាត់ ខ្មៅដៃ ក្ដារធ្នួន ស្វាបប៉ាកការ ឬក្រដាស់ ឯវត្ថុសំរាប់បង្រៀនត្រូវគ្រូបង្គាប់សិស្ស ឲ្យរកយកមកទុកនៅកន្លែងរៀនជាមុន គួររកឲ្យបានចំនួនរបស់គ្រប់ចំនួនសិស្ស ឬក៏ឲ្យបានរបស់មួយសម្រាប់សិស្ស ២ ឬ៣នាក់ ដើម្បីនឹងឲ្យសិស្សបានពាល់កាន់របស់នោះ សង្កេតមើលជាក់ប្រាកដគ្រប់គ្នា បើរបស់នោះនឹងយកមកបង្ហាញពុំបានទេ ប្រៀបដូចជាសត្វសេះឬដំរីនោះ គ្រូត្រូវគូរគំនូរយ៉ាងធំនៅក្ដារខៀនបញ្ជូរបង្ហាញឲ្យសិស្សពិនិត្យមើលក្នុងវេលាបង្រៀនវត្ថុស្វាធ្យាយន៍ គ្រូមិនត្រូវនិយាយច្រើនទេត្រូវតែចោទសួរសិស្សប្រើសិស្សឲ្យនិយាយ មុនដំបូងគ្រូយករបស់

ដែលបង្រៀនមកដាក់នៅមុខសិស្សឲ្យរៀនសង្កេតមើល ហើយប្រើឲ្យនិយាយតាមដែលបានពិនិត្យទៅហើយបានដឹងដូចម្ដេចៗ សេចក្ដីត្រង់ណាដែលគ្រូចង់ឲ្យសិស្សដឹង គ្រូត្រូវសួរណែនាំឲ្យសិស្សរកឃើញដោយខ្លួនឯង បើកាលណាគ្រូសង្កេតទៅឃើញថាសិស្សនិយាយច្រើនពេក ឃ្លាតចេញអំពីសេចក្ដីដែលគ្រូបង្រៀននោះ គ្រូត្រូវនាំសិស្សឲ្យនិយាយចូលមករកសេចក្ដីបង្រៀនវិញ ដួនមានសេចក្ដីត្រង់ណាមួយពិបាកណាស់សិស្សនឹងអាចរកខ្លួនឯងពុំឃើញនោះ គ្រូត្រូវអធិប្បាយប្រាប់តាមកុំបង្អង់ឲ្យខាតពេលឥតប្រយោជន៍ ។

សេចក្ដីដែលត្រូវជៀសវាង.- ១-១- សេចក្ដីត្រង់ណាដែលគួរល្មមដឹងថាសិស្សចេះប្រាកដហើយ មិនត្រូវសួរដដែលៗឲ្យយូរពេកទេ ប្រៀបដូចជាក្រដាស់ពណ៌ស ក្ដារខៀនបញ្ញពណ៌ខ្មៅ មាន់មានជើងពីរ គោមានជើង៤ .។ល។

១ ២.- សេចក្ដីត្រង់ណាវិញដែលជាសំខាន់សិស្សពុំទាន់ស្ដាប់បានប្រាកដគ្រូមិនត្រូវប្រូតរូតឲ្យរហាស់ពេកទេខុសអំពីក្បួនបង្រៀន ពីព្រោះសិស្សត្រូវចាប់រៀនពីការដែលបានស្គាល់ ហើយបន្តភ្ជាប់ទៅការដែលពុំទាន់ស្គាល់ពុំទាន់ដឹងនៅឡើយ ។

១ ៣- គ្រូពុំត្រូវបណ្ដោយឲ្យតាមតែសិស្សសួរហើយចេះតែនិយាយពន្យល់វែងទៅៗ ហួសអំពីកំណត់សេចក្ដីដែលបម្រុងបង្រៀនក្នុងពេល

វេលាមួយៗ ហេតុនេះគ្រូត្រូវតែងសេចក្ដីបង្រៀនជាមុនតាមគោលដូចមានខាងក្រោម

## ជំពូក១– អំពីកូនសិស្សពិនិត្យឃើញឯងៗ.

ក– ដោយបានពិនិត្យមើលនឹងភ្នែក. គ្រូសិស្សនិយាយអធិប្បាយអំពីសម្បុរទ្រង់ទ្រាយ ទំហំ (ប្រៀបនឹងវត្ថុដែលបានរៀនរួចហើយ) របស់នោះតើស្អាតឬក៏ ?.

ខ– ដោយបានពាល់ស្ទាបមើល– គ្រូសិស្សនិយាយថារបស់នោះរលីង គគ្រាត រឹងឬទន់ ក្ដៅឬត្រជាក់ ?

គ– ដោយបានលើកថ្លឹងនឹងដៃមើល. គ្រូសិស្សនិយាយថារបស់នោះក្រាស់ឬស្ដើង ធ្ងន់ឬស្រាល (ប្រហែលនឹងឬជាងរបស់អ្វីមួយដែលបានរៀនរួចហើយ ?

ឃ– ដោយបានហិតក្លិនមើលនឹងច្រមុះ– តើឃើញមានក្លិនដូចម្ដេច ប្រហែលនឹងក្លិនអ្វី ?

ង– ដោយបានភ្លក់មើលនឹងអណ្ដាត, (គ្រូភ្លក់តែរបស់ដឹងថាជាមិនពុល) តើឃើញមានរសជាតិដូចម្ដេចប្រហែលនឹងរសជាតិអ្វី ?

ច– ដោយបានស្ដាប់មើលនឹងត្រចៀក កាលណាយកបន្ទាត់ទៅគោះរបស់នោះឬក៏ទំលាក់របស់នោះទៅលើតុ តើឮសូរដូចម្ដេចប្រហែលនឹងសូរអ្វីដើម្បីនឹងសំ

គាល់ឲ្យបានទៅថ្ងៃក្រោយតាលណាឮសួរ ។

## បំពួក ២.- អំពីប្រយោជន៍យកមកប្រើការ

ត្រូវឲ្យសិស្សរកប្រយោជន៍ក្នុងចំណែកមួយៗនៃវត្ថុដែលរៀន នោះ តើគេយកមកប្រើការធ្វើអ្វីខ្លះ ។

នៅថ្នាក់អាទិកដ្ឋានត្រូវបង្រៀនបន្ថែមពីរបំពួកទៀត ។

## បំពួក៣-ហេតុដែលបណ្ដាលកាលណាដាក់វត្ថុនោះទៅក្នុងទឹក

តើវត្ថុនោះរលាយឬទេ រលាយក្នុងទឹកក្ដៅឬទឹកត្រជាក់ ។

## បំពួក៤-ហេតុដែលបណ្ដាលកាលណាដាក់វត្ថុនោះទៅក្នុងភ្លើង

តើឃើញដូចម្ដេច ឮសូរដូចម្ដេច ធុំក្លិនដូចម្ដេច នៅវេលានោះ ។

នៅវេលាណាដែលបានសួរសិស្សឲ្យឆ្លើយ ឬបានពន្យល់សិស្សសូមគ្រូសរសេរនៅក្ដារខៀនបញ្ជរ ពាក្យណាដែលសិស្សពុំសូវស្គាល់ច្បាស់នៅឡើយ ដើម្បីនឹងឲ្យសិស្សចេះចាំពាក្យនោះយកទៅប្រើការបានត្រឹមត្រូវទៅថ្ងៃក្រោយឥតមានខ្វាចក្រែងគាន់ប្រឡំឡើយ ។

លុះបង្រៀនចប់ហើយ បើលោកគ្រូយល់ឃើញថាគួរឲ្យសិស្សកត់សេចក្ដីយកទៅរៀន នោះសូមលោកគ្រូសរសេរនៅក្ដារខៀនបញ្ជរសេចក្ដីយ៉ាងសង្ខេបខ្លី រើសយកតែការសំខាន់ជាងគេ ឲ្យសិស្សចម្លងដាក់សៀវភៅរៀនខ្លួន.

## អំពីតាំងមន្ទីទុកវត្ថុសំរាប់បង្រៀន

ដូចបានអធិប្បាយរួចមកហើយថាការបង្រៀនវត្ថុស្វាធ្យាយន៍ បានតែមានវត្ថុទើបបង្រៀនបាន ហេតុនេះនៅសាលារៀននិមួយៗ ត្រូវគ្រូខំរកវត្ថុមកទុកសំរាប់បង្រៀន ត្រូវរកសន្សំបន្តិចម្ដងៗ វត្ថុមួយមុខៗ ត្រូវដាក់ក្នុងកូនដបថ្មបំពង់តូចមួយ ត្រូវតំរៀបនៅក្នុងថ្នាក់ទូតាមដោយពួកវត្ថុ ឧបមាដូចជាគ្រឿងបរិភោគ ( អំបិល ប្រេង ស្រូវ អង្ករ ស្ករ ម្រេច ពោត ។ ល។ ត្រូវដាក់មួយពួក ។

វត្ថុមានសរសៃ- ( សូត្រ កប្បាស អំបោះ គរ រោមសត្វ ។ ល។ ត្រូវដាក់មួយពួកផ្សេង ។

វត្ថុសំរាប់អុចបំភ្លឺ- ( ប្រេងកាត បន្ទុះ ចង្កៀង ក្រមួន ទៀន ជ័រ ។ ល ។ ត្រូវដាក់មួយពួកផ្សេងៗ ។

វត្ថុសំរាប់ដុត- ( ឧស ធ្យូង ធ្យូងថ្ម ។ ល ។

វត្ថុសំរាប់សង់ផ្ទះ· ឫស្សី ផ្ដៅ ស្លឹក អិដ្ឋ ថ្ម ថ្មកំបោរ ស៊ីម៉ង់ត៍ ។ល។

លោហធាតុ- ( ដែក ស្ពាន់ សំណ ប្រាក់ ។ ល ។

## អំពីបង្រៀនមុខភូមិសាស្ត្រ

ប្រយោជន៍- ការបង្រៀនភូមិសាស្ត្រ មានប្រយោជន៍ឲ្យសិស្សស្គាល់ស្រុកភូមិដែលខ្លួននៅ ស្គាល់ភ្នំ ស្គាល់ទន្លេ ព្រែកដែលហូរកាត់ ស្គាល់

របរធន់ធាន ផ្លូវគាត់ពីភូមិមួយទៅភូមិមួយ បើសិនណាជាមិនបេះវិញ ប្រៀបដូចជាអ្នកក្រៅ ទើបនឹងចូលមកនៅស្រុកគេឥតមានស្គាល់អ្វីសោះ ទៅជាពុំមែនអ្នកនៅក្នុងស្រុករបស់ខ្លួនឡើយ ប្រយោជន៍មួយវិញទៀតឲ្យស្គាល់ថានគរកាលពីដើមគឺយ៉ាងនោះៗ ប្រៀបនឹងនគរសព្វថ្ងៃនេះខុសពីគ្នាយ៉ាងណាខ្លះ នឹងបានបេះស្រឡាញ់នគររបស់ខ្លួនខំគិតឲ្យបានចំរើនឡើង លុះរៀនចប់អំពីនគរខ្លួនរួចហើយ ទើបរៀនអំពីនគរដែលនៅជិតខាង យកសេចក្តីមកប្រៀបមើលនឹងនគររបស់ខ្លួនផង ។

របៀបបង្រៀន– នៅថ្នាក់កុមារដ្ឋាននឹងបរិវុឌ្ឍណដ្ឋាន ត្រូវបង្រៀនសិស្សឲ្យស្គាល់ទិសទាំងបួនឲ្យសង្កេតមើលទីដីនៅជុំវិញខ្លួន នឹងឃើញមានកន្លែងខ្លះទាបខ្លះខ្ពស់ ខ្លះមានទឹកដក់នៅ ខ្លះមានទឹកហូរ នឹងបានស្គាល់ដូចម្តេចគេហៅថាភូមិ ថាភ្នំ ទន្លេ ព្រែក បឹង កោះ ត្រើយ ផ្លូវដើរ ផ្ទះផ្សារ ។ ល ។

នៅថ្នាក់អាទិកដ្ឋានត្រូវបង្រៀនអំពីប្រទេសកម្ពុជា នឹងប្រទេសជិតខាង ដែលនឹងបង្រៀនឲ្យមានប្រយោជន៍ ៖ លោកគ្រូមិនត្រូវគ្រាន់តែបង្អុលប្រាប់សិស្សឲ្យទន្ទេញមេរៀនក្នុងសៀវភៅ ពីត្រឹមនេះដល់ត្រឹមនោះទេ សូមលោកគ្រូគូរផែនទីនៅក្តារខៀនបញ្ឈរ ហើយកាន់បន្ទាត់មួយបង្អុលបណ្តើរនិយាយពន្យល់បណ្តើរ ឲ្យសិស្សស្តាប់ហើយគូរតាមនៅក្តារឆ្នួនរៀនខ្លួន បើលោកគ្រូមិនសូវប្រសប់គូរទេ សូមគូរនៅក្តារខៀនបញ្ឈរមុន

ពេលបង្រៀន បើមិនបានជាត្រឹមត្រូវណាស់ឲ្យតែប្រហែលល្មមក៏បានដែរ លុះបានបង្រៀនយ៉ាងនេះរួចហើយ ទើបមើលសេចក្ដីមេរៀនឲ្យសិស្ស ស្ដាប់ជាងក្រោយ ។

## អំពីបង្រៀនរាជពង្សាវតា

ការរៀនរាជពង្សាវតា មានប្រយោជន៍នឹងឲ្យសិស្សស្គាល់ ប្រទេសរបស់ខ្លួនជាដើម ចាប់តាំងពីកកើតឡើងរៀងរហូតលុះមកដល់សព្វថ្ងៃនេះ នឹងបានដឹងថាស្ដេចណាទ្រង់ឡើងសោយរាជ្យសម្បត្តិពីឆ្នាំណាទៅដល់ឆ្នាំណា តំណាងស្ដេចណា បានតាំងទីក្រុងនៅឯណា បានរៀបចំប្រទេសដូចម្ដេច មានកើតចំបាំងនឹងប្រទេសណា ពីឆ្នាំណា ពីព្រោះហេតុអ្វី បានកសាងអ្វី ទំនុំទំនៀមអ្នកស្រុកដូចម្ដេច របៀបការត្រួតត្រាក្នុងប្រទេសបែបយ៉ាងណា ។ ល ។

នៅថ្នាក់កុមារដ្ឋាន– សូមលោកគ្រូនិទានឲ្យសិស្សស្ដាប់អំពីរឿងរ៉ាវពីដើមដែលមាននិយាយក្នុងស្រុកក្នុងភូមិគេៗមក តើកាលពីដើមស្រុកភូមិដូចម្ដេច មានផ្ទះមានផ្លូវថ្នល់ដូចសព្វថ្ងៃនេះឬទេ ហេតុដូចម្ដេចបានជាភូមិដែលនៅឈ្មោះហៅថាដូច្នេះមានរឿងពីដើមគេនិយាយថាដូចម្ដេច ។ល។ សិស្សនៅថ្នាក់បរិច្ឆណដ្ឋាន នឹងអាទិកដ្ឋានត្រូវឲ្យរៀនតាមសៀវភៅរៀងថ្នាក់ សូមគ្រូនាំសិស្សឲ្យចេះស្រឡាញ់ ប្រទេសខ្លួនស្រឡាញ់ជាតិ

ទំរៀនសូត្រឲ្យកើតមានចំណេះវិជ្ជា ដើម្បីនឹងធ្វើឲ្យចំរើនប្រយោជន៍ដល់ប្រទេស នឹងបានកាន់តែថ្កើងរុងរឿងឡើងតទៅ ៗ

លី - ម៉ាធិពូង៍

ស្រង់ពីកិច្ចសិក្សាបឋមវិជ្ជា បារាំងសែស-ខេមរៈ

ខែយូវាំង - សូយេ៊ុតឆ្នាំ ១៩៣៤

ឥង - ឈុំ

## ឧត្តមដ្ឋាន

# បុណ្យបុះផែ

ឧកាសបុណ្យដល់ហើយ ក្នុងទន្លេនៅមុខវាំងសឹងមានរបៀបរៀបចំ អឹកធឹកលើទឹកលើគោកភាពប្លែកចំឡែកពីធម្មតា ទាំងទូកនាវា ទាំងទីស្ថាន ៗ នាំមករសំញៀញបង្គុំស្រួប នៅអែបនែបនឹងព្រះទីនាំងសុខគ្រម ទូកតែហោ៊ កបាល់នូវទង់ជ័យពណ៌ប្រាល ខៀវសបក់រវិប បត់ផិតយាមរក្យាព្រះដំណាក់ផៃ ៗ

មានរោងក្រសាលសង់ពាសព័ទ្ធនូវពណ៌នានា មានក្បាច់របនាក្បឿវល្លិស្លឹកឈើនឹងភ្លើងអគ្គិសនី ៗ ពេលប្រណាំងទូកដល់ហើយ ទូកង ទូកមួងចេញត្រសងទៀបមុខព្រះពន្លា បីដូចនាគត្រាច់ក្នុងជលស័យ ៗ សត្វសូរប្រាក់គ្រឹបៗអ្នកអុំគោះទឹកជាចង្វាក់ មានអ្នករាំបាក់ក្បាច់កណ្ដូបសេះឈរទន្ទេងជាទីសំណើចនៃអ្នកមើល ៗ ទូកអុំប្ដូរទូកងលំអនឹងខ្នុកម្រក្សណ៍ខៀវស្រិល ក្បាលកន្ទ្បើយទន្ទុំ បន្សំនឹងហ្នាប៉ាក់ក្រលបរបនាស្ទផ្កាមាសក្លីព្រិចៗ លួនលឿនរំលេចគួរទស្សនាគយគន់មិនចង់ដាក់ភ្នែក ៗ ទូកមួងច្រើនរបស់ចាម ពុំសូវមានក្បាច់ក្បូរទេ តែសរសេរចង្វាក់ស្ទើដៃក្រៅវិស័យ ព្រោះពួកចាមសឹងជំនាញជាញជ័យខាងវៃវទូក ៗ មនុស្សមើលខ្មីលច្របូលដូចទឹកហូរពុំអាចគិតគូរចំនួនឡើយ តាមតែក្សរមាត់ប្រាំង

សឹងតែណែនណាន់តាន់តាប់ ដ៏មានពស្ត្រាភរណ៍លាយលេចចំរុះពណ៌នានា គណនាដូចកំពលជំនួយពាសមាត់ទន្លេ ៗ ឯអាកាសបក្សាយន្ត្រហើរផ្ទួល ធ្លាក់បន្ទឹសព្ទគគ្ហារស្ទើរស្រុតប្រឹថពី ៗ ពគ្រឹក្ហឹដូចថ្ងៃ ដោយប្រទីបផ្កាឈា ដ៏រចនាជារូបសត្វ រូបប្រាសាទក្លីហ្រោងព្រាតធ្លុះប្រុះទាំងជលស័យ នឹងសត្វត្បូងត្រឹទ្ធិពីរោះល្ហើយល្ហើងស្ទើរព្រះចន្ទចាំងរៃបង ព្រមទាំងខ្យល់ទក្ខរបក់ផ្សព្វកាយ ជាឱកាសសប្បាយមួយនៃស្រុកយើង ៗ

## ពន្យល់ពាក្យ

អុកធីក ឬ អកអធីក=(ម.ថ អុកៈធីក ឬ អុំកអៈធីក)-គឺ ហ៊ុកហ៊ាក់

មករ ឬ មង្ករ = ន .ឈ្មោះត្រីសមុទ្រមួយយ៉ាង មានខ្លួនធំក្បាលទ្វី ក្រមុំបញ្ចេញទឹកបង្ហូមស្បាញគួរស្ញើម ឆ្លាមមករ,

ជលស័យ ឬ ជលាស័យ=( ម.ជលាសយ : ជល+អាសយ:ទន្លេ )

បង្អាក់= ផ្អាកបង

ហ្វា ធ៉ក់= ន. សំពត់ដែលគេធ៉ក់ពាសមុខទូក

ពស្ត្រាភរណៈ ឬ ពស្ត្រាភរណ៍:សំពត់និងគ្រឿងប្រដាប់កាយ ។

យន្ត ឬ យន្ត្រ=( ម.ថ.យន្ត ) ន. គ្រឿងប្រដាប់ដែលកកើតបាន ដោយកម្លាំងចក្រប្រគបគ្នា ។

ប្រឹថពី ឬ ប្រថពី= ន. ផែនដី

កង្ហារ= ប្រដាប់មានស្លាបវិលដោយកំឡាំងខ្យល់

វេវចនៈ ស៊ុកឈឹក : ហ៊ុកហាក់ - រុងរឿង - ឧឡារិក

✕

✕ ✕

## ល្បែងប្រណាំងទូកង

ល្បែងប្រណាំងទូកនេះ ជាល្បែងសម្រាប់លេងកំសាន្តមួយ យ៉ាងឧឡារិករបស់ជនជាតិខ្មែរចាស់ ក្មេង - ប្រុស-ស្រី គេទុកជាទំនៀមទម្លាប់ខាងល្បែងមួយដ៏ប្រសើររបស់ជនជាតិខ្មែរ តាំងពីបុរាណសម័យរហូតមក ដល់សព្វថ្ងៃនេះ ក៏មាននិយមលេងជាច្រើន រាល់ខេត្ត រាល់ស្រុក ក្នុងដែនកម្ពុជានេះ ។ មិនតែប៉ុណ្ណោះសោត សូម្បីជនជាតិដទៃដូចយ៉ាងជនជាតិ ចាម ជ្វា ជាដើម ក៏ចូលចិត្តលេងប្រណាំងទូកដូចខ្មែរយើងដែរ ។

ឯការលេងប្រណាំងទូកនេះ ជនជាតិខ្មែរច្រើនតែប្រណាំង ក្នុងគ្នា នៅរដូវវស្សា ដែលទឹកឡើង លិចល្ហាចល្ហឹមសព្វទីភូមិឋាន ។

ក្នុងថ្ងៃបុណ្យភ្ជុំបិណ្ឌម្តង មហាជនជាតិខ្មែរ ទាំងក្មេង·ចាស់·ប្រុស ស្រី គេដើរប្រមូលគ្នារើសរកទូកប្រណាំងយ៉ាងលឿន ហើយហៅគូកន ដាក់បំណុះឲ្យស្មើគ្នា បើទូកម្ខាងមានគ្នាម្ភៃនាក់ ទូកម្ខាងទៀតក៏ត្រូវឲ្យមាន គ្នាម្ភៃនាក់ដែរ ឬលើសខ្វះគ្នាបន្តិចបន្តួចក៏គេសុខចិត្តព្រមព្រៀងលេង តែ គេច្រើនឲ្យពួកកុមារីនៅក្រមុំពេញជំទង់ អង្គុយខ្ទង់ទូកខាងមុខ ពួកកុមារ

អង្គុយខ្ជន់ទូកខាងក្រោយ ហើយអ្នកកាប់ចង្កូតទូកប្រណាំងនោះ គេច្រើនយកច្រវ៉ាដំដងវែងមកកាប់ចង្កូតទូកផង ឯអ្នកក្រៅពីនោះ កាន់ច្រវ៉ាគ្រប់ដៃរៀងៗខ្លួន ហើយមានម្នាក់ទៀត ហៅថាគ្រូចង់ចត់ ឬអ្នកមានសំដី ថ្វីមាត់គ្រាន់បើអង្គុយលុតជង្គង់ត្រង់ច្រកក្បាលទូក អ្នកនេះកាន់ច្រវ៉ាលនយ៉ាងល្អហើយជួតក្បាលផង សម្រាប់ស្រែកយកជ័យឬ ស្រែកថា "មួយយ៉ូៗ" កងកាលដែលកំពុងប្រណាំងគ្នា ៗ

## ពន្យល់ពាក្យ

ទឡ្ហិក = រុងរឿង – ហ៊ុកហ៊ាក់

បុរាណសម័យ = សម័យជាន់ដើម – ជំនាន់បុព្វបុរសរបស់យើង

និយម = រាប់អាន – អនុលោមតាមធម្មតា

រដូវវិស្សា = ឬវស្សានរដូវ = រដូវភ្លៀង

បិណ្ឌ (ម.ថ.បិនឌ ឬបិន) ន.ការប្រមូលឲ្យមូលឬពូតឲ្យជាដុំ (ភ្ជុំបិណ្ឌ ពាក្យនេះខ្មែរយើងឲ្យឈ្មោះពិធីធ្វើទានមួយយ៉ាង ចាប់តាំងពីថ្ងៃ ១ រោចខែភទ្របទទៅដល់ថ្ងៃខែដាច់ (១៥ថ្ងៃ) ហៅថា កាន់បិណ្ឌ ថ្ងៃ១៥ រោចខែភទ្របទ ហៅថាថ្ងៃភ្ជុំបិណ្ឌ)

សន្តានពាក្យ = ល្បែង = លេង-បន្ទុង.ប្រលែង

## មជ្ឈមណ្ឌលទី ២

# ទឹកទន្លេសាបហក់មកវិញ

រាល់រដូវ ទន្លេសាបមានសោភាពល្អមើល ៗ គេឃើញផ្ទះខ្ពស់ៗត្រដែត វត្តភាពស្រង្គូតគួរឲ្យស្រងេះស្រងោច ព្រះស្តូបស្តុកស្តម្ភព្រះបដិមាខ្លះធំសម្បើមដ៏មានព្រះភក្ត្រញញឹមក្សេមក្សាន្ត ៗ ប៉ុន្តែមានរដូវមួយដែលសោភាពរឹតតែប្លែកចំឡែកទៀត គឺរដូវភ្លៀងដែលមេគង្គជន់ពេញរង្វាល់ ទឹកជំនន់នៃមេគង្គផ្ទុញទឹកដែរៗមកប្រសព្វខ្សែទឹកហូរខ្លាំងកម្លាំងឥតគណនា រុញខ្សែទឹកទន្លេដ៏ជាប្រធាននៃដៃទន្លេប្រសព្វឲ្យត្រឡប់ហូរចាក់ទៅទន្លេសាប ទៅបំពេញផ្ទៃបឹងទីងល្ហុបដ៏ទំនាបវិញ ៗ ទឹកជំនន់ឡើងលិចពេញបន្ទុកហើយក៏ត្រឡប់មកវិញ នៅឱកាសដែលទឹកត្រឡប់មកវិញនោះ គេឃើញមានបុណ្យដ៏រុងរឿងដែលព្រះចៅផែនដីយាងចុះទៅប្រថាប់ក្នុងព្រះទីនាំងនាវា ដ៏មានទូកម៉ឺនសែនចតហោមរោមជាយសបរិវារ គឺជាបុណ្យព្រ័ត្យដែលគេបង់សន្ទូងកាត់ទន្លេ ហើយគេបណ្តាច់ដោយមុខព្រះច័ន្ទ ៗ ជំនន់នៃទន្លេមេគង្គជាជំនន់មានគុណដ៏ប្រសើរទឹកនោះនាំដីជាតិទៅបំរើនដីដំណាំ ទីងនាំឲ្យកើតត្រីជាលាភកោងដែលជាអាហារនៃអ្នកស្រុកកម្ពុជា ៗ ជំនន់ឡើងល្ហុបលិចរហូតដល់ព្រៃនោះនៅវេលាទឹកលិចព្រៃ គេឃើញតែចុងព្រឹក្សាលេចពីទឹកប្រិមៗជាឱកាសសប្បាយ

ទឹងគ្រាប់កាត់ព្រៃទៅបានផុតទើសចាស់ឡើយ

## ពន្យល់ពាក្យ

ទឹកទន្លេហក់ = ទឹកទន្លេសាបហូរត្រឡប់មកទន្លេមេកុងវិញ ។

សារភាព =(ម-ថ-សារភាព)—ការៈពិត—ដំណើរឬសេចក្តីពិតសារភាព

ល្អ=ការៈឬដំណើរល្អ ។

វត្តភាព = (ម-ថ-វត្តភាព)—វត្ត—ន—ការប្រព្រឹត្ត—មុខការ=កិច្ចដែល

គួរធ្វើ-នាទី វត្តភាព—ការៈគួរឲ្យស្រងេះស្រងោច

ស្តូប = ការបនាដោយឥដ្ឋ-ស៊ីមង្តិសំរាប់បញ្ចុះធាតុ(ចេតិយ)

ស្តុកស្តម្ភ =មាំមួន...

បដិមា = ព្រះពុទ្ធរូប...

ផ្ទាញ់ = រុញសង្កត់

ប្រថាប់ = គង់នៅ

បរិវារឬបរិពារ = អ្នកចោមរោមកំដរ ឬ ហែហមជាកិត្តិយស

វេវចនៈ: ស្តុកស្តម្ភ—មាំមួន រឹងត្អឹង រឹងប៉ឹង...

សទិសសព្ទ =កោដិ-ន—ប.សំ ដប់លានត្រូវជាមួយកោដិ

កោដ្ឋ.ន.កោដ្ឋមាស សុវណ្ណកោដ្ឋ ។ កោត.កិ.កោតញញើត ។

សួរចោទ.—នៅរដូវណាដែលទន្លេមេកុងហូរចាក់ទៅទន្លេសាប ។

ទឹកទន្លេសាបហក់មកវិញនៅរដូវណា ៗ វេលានោះមានបុណ្យត្រី ជាចឡារិកនៅទន្លេចតុមុខ ៗ ជំនន់ទន្លេមកពុំដឹងមានប្រយោជន៍ដូចម្តេច ៗ

⁂

## បុណ្យចូលឆ្នាំណាវ

នៅថ្ងៃចូលឆ្នាំនាម៉ឺនសព្វមុខមន្ត្រី ចូលគាល់ហ្លួងជាអម្ចាស់ជីវិតក្នុងវាំង ៗ នៅថ្ងៃជាគំរប់បី គឺថ្ងៃឡើងស័ក ពេលារសៀល ហ្លួងយាងទៅធ្វើពុទ្ធបូជាក្នុងព្រះវិហារវត្តវិស៊ិន ដ៏មានក្បួនហែជាចឡារិក ៗ នោះទៅមុខបង្អស់ គេឃើញដំរីប្រាំសឹងប្រដាប់ដោយគ្រឿងល្អប្រសើរបន្ទាប់មកពួកទាហានសឹងកាន់ទង់ជ័យ ប្រទេសជាតិនៅដែលជាប់មកទៀតទាហានកាន់លំពែងស្នែងក្របី ពួកមហោស្រពពួកពលស្នែងក្រហមសឹងកាន់ស្គរនៅដៃ តមកទៀតពួកនាម៉ឺនអញ្ជើញគ្រឿងដេរអមឡោមហ្លួងដែលគង់លើព្រះសាលៀងមាស បិទបាំងដោយក្លស់សមួយគូ ក្រោយបំផុតមកទៀត ពួករបាំនិងពួកចម្រៀង ៗ

ក្នុងឧកាសនោះគប្បីគេចង់យល់ចង់ឃើញ ព្រោះកាលចេញទៅក្បួនហែដើរទៅដូចប្រក្រតីរហូតដល់វត្ត ប៉ុន្តែលុះត្រឡប់មកវិញ ពួក

កញ្ញានានា ដៃកាន់និទៅនូវគន្ធមាលាចាំស្កាត់ក្បួនហែ ហើយថ្វាយសព្វ សាធុការដោយបាចសាចសុគន្ធពិដោរ ដូចជាប្រឡែងលេងសប្បាយ ទៅលើអង្គព្រះពជា លើពួកទាហាន លើពួកក្បួនហែ នូវអស់ពួកអ្នកឈរ មើលយ៉ាងហ្នឹងហើយគឺសណ្ដាប់បុណ្យចូលឆ្នាំ ។

## ពន្យល់ពាក្យ

គាល់ហ្វង៍ - អង្គុយចាំស្ដាប់ព្រះឱង្ការហ្វង៍ - គាល់ព្រះអង្គម្ចាស់ ទៅលេង ទៅសួរព្រះអង្គម្ចាស់.........

ពុទ្ធបូជា = (ម.ថ.- ពុត - ធ) ន. បូជាចំពោះព្រះពុទ្ធ

ឧឡារិក = (ម- ថ. អ៊ុឡារិក ) = អឹកធិក - ហ៊ឹកហាក់

មហោស្រព=( ម.ថ. មៈហោស្រប់ ).ន.របាំ

សាលៀង = គ្រែសង៍ ហៅសិវិការវិញក៏បាន

កញ្ញា = ន.ស្រីក្រមុំ – ស្រីជំទង់

ដៃកាន់និទៅ= ដ៏មាននៅដៃ

គន្ធ = ( ម.ថ. គន់ធៈ ) = ក្លិនគ្រឿងក្រអូប

មាលា = ផ្កាកម្រង៍

គន្ធពិដោរ = ក្លិនក្រអូបល្អ

មជ្ឈមណ្ឌល

## រៀនមើល ហាត់ភាសា

# ព្រះមហាក្សត្រនឹងប្រជាជន

ព្រះមហាក្សត្រដែលទ្រង់គ្រប់គ្រងប្រទេសនិមួយៗព្រះអង្គជាទេពតា ដោយសន្មត ទ្រង់នាមថា ((ព្រះរាជា)) ព្រោះទ្រង់ប្រកបដោយការសង្គ្រោះដោយសង្គហវត្ថុ៤យ៉ាង គឺប្រទានទេយ្យវត្ថុ- មានព្រះវាចាគួរឲ្យចង់ពុចង់ស្តាប់ – ទ្រង់ប្រព្រឹត្តអំពើជាប្រយោជន៍ ទ្រង់តាំងព្រះអង្គស្មើ ៗ គឺប្រើឬកពា ឲ្យល្មមពេញចិត្ត ប្រជាជន ។

ទ្រង់ដម្រង់ប្រជាជន ដោយទសពិធរាជធម៌ ធម៌សម្រាប់ព្រះរាជា មាន១០យ៉ាងគឺអំណោយទាន រក្សាសីល ៥ជានិច្ចចំណាយព្រះរាជទ្រព្យ ទំនុកបំរុងប្រទេស មានសេចក្តីទៀងត្រង់ទន់ភ្លន់សភាព- រក្សាឧបោសថសីលតាមកាលកំណត់ម្តងៗ មិនកំដៅក្រហាយប្រជាជន-មិនបៀតបៀនអ្នកដទៃ មានសេចក្តីអត់ធន់ មិនបំពានលើធម៌លើច្បាប់ ។

ដោយហេតុនេះទើបទ្រង់ព្រះនាមថា ជាបុព្វការីរបស់ប្រជាជន ប្រជាជនដែលបានសេចក្តីសុខ ដោយសារការគ្រប់គ្រងរបស់ព្រះរាជានោះ ហើយជាអ្នកដឹងឧបការគុណក៏តាំងចិត្តស្មោះត្រង់ចំពោះរាជការផែន

ដី ជួយយកអាសាការពារដែនដី ដោយស្មោះស្ម័គ្រ មានស្វាមីភក្ដិចំពោះព្រះរាជា ចំពោះរាជការដែនដី ឥតមានរើងទង់ឲ្យផ្លាស់ប្ដូររាជការ យ៉ាងនេះហៅថា កតញ្ញូកតវេទី ចំពោះព្រះរាជា ជាម្ចាស់ជីវិតរបស់ខ្លួន ។

## អាននិងពន្យល់ពាក្យ

សង្គហវត្ថុ= (អ-ថ សង់ គះហះ)ន: អង្គនៃសេចក្ដីសង្គ្រោះ មាន៤យ៉ាង ...

ទេយ្យវត្ថុ=(អ.ថ.ទ័យ យះ)ន.វត្ថុទុកធ្វើជាទាន។ទសពិធរាជធម៌=(ទស ពិធះរាជធ័រ)ន. គឺធម៌ ១០ប្រការសម្រាប់ព្រះរាជា ។

សីល: ការកាន់ ឬប្រព្រឹត្តល្អដោយកាយវាចា ..........................

ឧបោសថសីល= (អ-ថអ៊ុបោស្សុតថសីល) សីលឧបោសថសីល សម្រាប់រក្សាចំរះចិត្ត ។

បុព្វការីរបស់ប្រជាជន= បានធ្វើសេចក្ដីទុកចំរើនផ្ដើមដល់ប្រជាជន ។

យកអាសា= ជួយឈឺឆ្អាលដោយស្ម័គ្រស្មោះអស់ពីចិត្តពីថ្លើម ។

ស្វាមីភក្ដិ= (ស្វាមី–ម្ចាស់ប្ដី) ស្វាមីភក្ដិ= សេចក្ដីស្រឡាញ់ស្មោះចំពោះម្ចាស់ ។

អវិចនះប្បកតា= មារយាទ កិរិយា-បែបបទសណ្ដាប់ធ្នាប់ ។

សទិបសត្វ ធន់=ក្រាំ ធន់ធ្ម៉ឺ ។ធន=ទ្រព្យធន់ធានា។ធុនបែបយ៉ាងកុំណើត

ជាមួយគ្នា តែមួយផុន ។សួរថា៖ ព្រោះអ្វីបានជាថាព្រះមហាក្សត្រជា ទេវតាដោយសន្មត? ដែលទ្រង់ព្រះនាមជា រាជានោះ គឺទ្រង់ប្រកបដោយ ការអ្វីខ្លះ? ធម៌សម្រាប់ព្រះរាជាមានប៉ុន្មានយ៉ាង? ប្រជាជនត្រូវប្រព្រឹត្ត ដូចម្ដេចចំពោះព្រះមហាក្សត្រ? ។ល។

រៀនមើល = សរសេរតាមសូត្រ

## អតីតប្រវត្តិនៃប្រទេសកម្ពុជា

កាលនោះមានលាវម្នាក់ លើកព្យុហសង្គ្រាមមកដណ្ដើមយកប្រទេស កម្ពុជា ។ លាវនោះតាំងខ្លួនជាក្សត្រិយ៍មួយព្រះអង្គ តាំងជាតិស្យាមប្រ-ទេស គឺជាតិសៀមនាំបណ្ដាលហេតុឡើង ទើបលាវហើយនិងយួន ដែលធ្លាប់ចំណុះចុះចូលប្រទេសកម្ពុជាពីដើម ក៏កំរើកចិត្តតាមសៀម ហើយដណ្ដើមយកផែនដីប្រទេសកម្ពុជានេះ ដោយចំណែកសាមល ពង្សប្រទេសពង្សផ្សេងៗ ក៏លែងចំណុះចុះចូលប្រទេសកម្ពុជានេះ ចាប់តាំង តែពីគ្រានោះមក ។ ប្រទេសខ្មែរកើតជាផែនដីតូចស្ដួចស្ដើងណាស់ ប្រ-ជារាស្ត្រក៏ក្រពិបាករៀងមក ។

ដល់មកផែនដីព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះបាទ

សម្តេចព្រះនរោត្តមបរមរាមាវតារ ទ្រង់ប្រកបដោយមហាករុណាដល់អាណាប្រជានរាស្ត្រ ដែលក្រីក្រពិបាកដោយស្រុកបាក់បែកនឹងសឹកសង្គ្រាមជារឿយៗនោះណាស់ជំនុំព្រមកុងសីយសេនាបតី ទ្រង់មានព្រះសុភអក្សរទៅចងសម្ពន្ធមិត្រនឹងមហានគរបារាំងសែស ។

អគ្គាធិវរដ្ឋ ព្យូហ (ហ) សាមលរាជ (ផ្ស)

ប្រទេសរាជ្យ(ផ្ស) អាណាប្រជានុរាស្ត្រ មហាករុណា សុភអក្សរសម្ពន្ធមិត្រ

---

## មជ្ឈិមដ្ឋានទី ១

**រៀនមើល = ហាត់ភាសា**

# រឿងត្មាត-ឆ្មានឹងបក្សី

នៅក្បែរត្រើយទន្លេគង្គា មានដើមជ្រៃមួយដើមធំមែកត្រសុំត្រសាយសាខាធំហើយដោយព្រោះជាទីអាស្រ័យនៅនៃបក្សីទាំងឡាយនឹងត្មាតមួយ ។ ដោយកម្មអាក្រក់ឲ្យផល ត្មាតនោះក៏ទៅជាខ្វាក់ ងងឹតងងុលក្រចករេចរឹលអស់រលីង ។ បក្សីជាតិទាំងឡាយដែលអាស្រ័យនៅនាដើមជ្រៃនោះមានចិត្តអាណិតអាសូរ តែងរំលែកចែកអាហារខ្លួនបន្តិច ៗ ម្នាក់ឲ្យដល់ត្មាតនោះជួយចិញ្ចឹមឲ្យមានជីវិតរស់នៅ ។

គ្រានោះមានឆ្មាមួយចូលមករកចាប់កូនបក្សីស៊ីជាអាហារ នៅក្នុងព្រៃឈើនោះ ៗ កូនបក្សីទាំងឡាយកាលបើឃើញឆ្មាដើរចូលមក ក៏កើតភ័យរន្ធត់រត់ផ្ទួផ្ទា កោលាហលពេញទាំងព្រៃ ៗ ត្មាតបានឮសូរសំឡេងគឹកកងខ្ទៀវខ្ទារដូច្នោះក៏ស្រែកសួរទៅថា “ អាណាមកធ្វើអ្វីឲ្យជ្រួលច្របល់របល់ដូច្នេះ ” ឆ្មាសម្លឹងមើលទៅឃើញត្មាត ក៏តក់ស្លុតញាប់ញ័រក្នុងចិត្ត ហើយគិតថា “ ឱអាត្មាអញដល់គ្រោះស្លាប់ហើយតើ ” តែថាដរាបណាភ័ក្តិភ័យន្តរាយមិនទាន់មកដល់ទេ ដរាបនោះបុគ្គលគប្បីប្រុងប្រយ័ត្នដល់ភ័យ នោះបើភ័ក្តិភ័យន្តរាយមកដល់ហើយ បុគ្គលគប្បីក្លាហានតស៊ូនឹងភ័យនោះ តាមគំនិតខ្លួនដែលបានគិតទុកមុនស្រេចហើយ ៗ

ឥឡូវនេះ អាត្មាអញចូលមកទល់ខ្លួនដល់ជិតក្តីស្លាប់ហើយ នឹងថយទៅក្រោយវិញក៏មិនបាន, ហើយចុះបើមានហេតុយ៉ាងណាកើតឡើងក៏តាមការណ៍ចុះ អាត្មាអញនឹងចូលទៅឲ្យដល់ត្មាតវៃអែបឲ្យស្និទ្ធស្និទ ៗ

ឆ្មារកឧបាយឃើញដូច្នេះហើយ ក៏ចូលទៅជិតត្មាតពោលពាក្យសំពះសួរថា” បពិត្រលោកម្ចាស់ ខ្ញុំបាទសូមជំរាបសួរ ” ត្មាតសួរថា ” ឯងជាអ្វី ? ” ឆ្មាឆ្លើយតបថា ” ខ្ញុំបាទជាសត្វឆ្មា ” ត្មាតក៏ហែងថា ” នែអាសត្វចង្រៃ ចូរថយចេញឲ្យឆ្ងាយទៅ បើមិនថយចេញទេ អាឯងត្រូវ

គ្រោះស្លាប់ឥឡូវមិនខាន ” ។

ឆ្មានិយាយអង្វរថា ” សូមលោកស្ដាប់ពាក្យខ្ញុំបាទសិន កាលបើឃើញថាគួរសម្លាប់ ខ្ញុំបាទក៏សុខចិត្តទទួលស្លាប់ឥតប្រកែក ” ។

## អាននឹងពន្យល់ពាក្យ

ភយន្តរាយ= ( អ.ថ. ភ័យយ័នតៈរាយ ) ន. អន្តរាយដែលគួរខ្លាច, អន្តរាយយ៉ាងសម្បើម ។

ជ្រៃ= ឈ្មោះឈើមានជ័រ ពួកពោធិ, ពួកល្វា មានពួររយីករយាក ឬតំទូពន្ធ ជ្រៃមានច្រើនយ៉ាង គឺជ្រៃពោធិ, ជ្រៃក្រឹម ជ្រៃលៀប ជ្រៃត្រាង ។

ព្រន់= ន រន្ធ, ប្រហោង : ព្រន់ឈើ, ព្រន់ ជាស

ត្មាត= ន. ឈ្មោះសត្វស្លាបធំ បរិភោគសាកអសុភជាអាហារ ។

កោលាហល= ( អ.ថ. កោឡាហល់ ) ន. សេចក្ដីភ្ញាក់ផ្អើលជ្រួលជ្រើម ។

✕

✕ ✕

## រឿងត្មាត-ឆ្មា នឹងបក្សី ( ចប់ )

ត្មាតស្ដាប់ហើយពោលថា “មើលនិយាយមកមើល, អាឯងចូលមក

នេះត្រូវការអ្វី?" ឆ្មាឆ្លើយថា ខ្ញុំបាទនៅត្រើយទន្លេគង្គានេះឯង ប្រព្រឹត្ត ព្រហ្មចរិយធម៌ជាប្រក្រតីមិនហ៊ានស៊ីសាច់ឈាមទេ, ខ្ញុំបាទបានឮបក្សីជាតិ សរសើរកិត្តិគុណលោកចំពោះមុខខ្ញុំបាទជារឿយ ៗ ថាលោកជាអ្នកចេះ ដឹងច្រើន, ចិត្តធ្ងន់ក្នុងធម៌ ល្មមទុកចិត្តស្និទ្ធស្នេហាយកជាវិសេសៈ បាន ហេតុនេះបានជា ខ្ញុំបាទមានចិត្តត្រេកអរចង់ចូលមកត្រង់ត្រាប់ស្ដាប់ធម៌ រៀនវិជ្ជាច្បាប់គតិលោកគតិធម៌អំពីសំណាក់លោក ដែលជាបុគ្គលចាស់ ព្រឹទ្ធាចារ្យមានការចេះដឹងស្ទាត់ជំនាញ ប្រសប់ប៉ិនប៉ាវក្នុងវិជ្ជាផ្សេងៗ ហេតុអ្វីក៏លោកបែរទៅជារករឿងកាប់សម្លាប់ខ្ញុំបាទដែលជាភ្ញៀវទៅវិញ? ព្រោះថាបុគ្គលគប្បីធ្វើបដិសណ្ឋារចំពោះភ្ញៀវ ទោះបីភ្ញៀវនោះ ជា សត្រូវដែលមកដល់ផ្ទះហើយ ដូចព្រឹក្សជាតិតែងឲ្យម្លប់ជាទីសំបតមិន រើសមុខ សូម្បីអ្នកកាប់ឈើក៏ដោយ, ម្យ៉ាងទៀតភ្ញៀវរិលត្រឡប់ចេញ ពីផ្ទះអ្នកណា ដោយក្ដីក្ដៅក្រហាយចិត្ត, ភ្ញៀវនោះឈ្មោះថាប្រគល់ឲ្យនូវ បាបអប្បមង្គល ដល់អ្នកម្ចាស់ផ្ទះនោះ ។

តាតនិយាយកាត់ថា " ឲ្យតែឈ្មោះថា ឆ្មាហើយសុទ្ធតែចូលចិត្ត ស៊ីសាច់ទៅជាអាហារទាំងអស់, នៅក្នុងព្រៃដើមជ្រៃនេះ មានសុទ្ធតែបក្សី អាស្រ័យនៅ ហេតុនេះបានជាអញហាមឃាត់យ៉ាងនេះ " ។

ឆ្មាស្ដាប់ពាក្យតាតហើយ ក៏ស្រពោនទុនដាក់មុខយកដៃស្ទាបត្រ

ចៀកតាំងសងខាង ក្រាបសំពះនិយាយបញ្ជាក់ថា ខ្ញុំបាទបានសិក្សាគម្ពីរធម្មសាស្ត្រចប់អស់ច្រើនហើយ រួមសេចក្ដីមកនៅត្រឹមតែមួយមាត់គឺ (អហិ-សា ) ការមិនបៀតបៀនគេ ជាធម៌ប្រសើរក្រៃលែង ។

កាលបើឆ្មានិយាយបន្ទន់ចិត្តគាត់ ឲ្យជឿជាក់ដោយប្រការផ្សេង ៗ ហើយ ក៏សរសៀរចូលទៅក្នុងព្រៃជ្រៃនោះបាន ក៏តាំងតែចាប់កូនបក្សីយកមកហែកស៊ីរាល់ ៗ ថ្ងៃ ។

ឯបក្សីទាំងឡាយដែលឆ្មាស៊ីកូន ក៏យំសោកខ្សៀវខ្សា ប្រជុំគ្នាសើបសួររកដំណើរដើមទងនៃការបាត់បង់កូន ៗ ឯឆ្មាលុះបានដឹងរឿងនោះហើយ ក៏បោលចេញពីព្រៃជ្រៃទៅខាងក្រៅភ្លាម បក្សីទាំងឡាយបបួលគ្នាគយគន់មើល ប្រទះឃើញតែឆ្អឹងកូននៅក្នុងព្រៃដើមជ្រៃនោះ ក៏ចោទប្រកាន់ឆ្មាតចាស់នោះថា ( ឆ្មាតខ្វាក់កញ្ចាស់នេះឯងដែលស៊ីកូនយើង ) ទើបព្រួតគ្នាសម្លាប់ឆ្មាតចាស់ចោលបង់សៀតពួងកាលនោះទៅ ។

## អាននឹងពន្យល់ពាក្យ

ព្រហ្មចរិយធម៌ = ( អ-ឋ-ព្រំម: ចរិយធ៌ ) ន. ការប្រព្រឹត្តដ៏ប្រសើរ

វិស្សាស: = ( អ.ឋ.វិស្សាស: គុ. ដែលជាទីស្និទ្ធស្នាល ៗ

បដិសណ្ឋារ = ( អ.ឋ.ប:ដិសនថារ: ) ន. ការទទួលរាក់ទាក់ ៗ

ធម្មសាស្ត្រ = ( អ.ថ ធម្មៈសាស ) ន. ឈ្មោះគម្ពីរមួយមានសេចក្តីសំដែងអំពីយត្តិធម៌ ។

អហឹសា = ( អ.ថ. អៈហឹង្សា ) ន. ការមិនបៀតបៀន ។

ត្នោតបង់ជីវិតព្រោះគប់មិត្តអាក្រក់ ដូចមានសាសិតបុរាណថា ៖ កុំទុកចិត្តបរទេស កុំទុកចិត្តអតិនេស្ត្រម៌ កុំទុកចិត្តអតិព្រាយ ។

( សាស្ត្រាច្បាប់ត្រីនេត្រ )

---

អាធិគគដ្ឋាន

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ១ – អំពីលោហធាតុ (ធាតុដែក)

នាម – ស្ពាន់ សំណ សំរិទ្ធ លង្ហិន ទង់ដែង ដែកស៊ីឡាត ដែកស័ង្កសី ប្រាក់ មាស ទង់ហ្វី ។

គុណនាម – រឹង ទន់ ស្រួយ ដាប់ មាំ ធ្ងន់ ស្រាល ច្រេះ ចាក់ ថែក ក្តៅ ត្រជាក់ រលីង រលោង រលើប ក្រាស់ ស្តើង ខ្មៅ ស ក្រហម លឿង ប្រផេះ ក្លឹស្រគាប់ ។

កិរិយាសព្ទ — ផុតដែក វាយដែក (ដំ) រំលាយមាស កាត់ស្ពាន់ ដំទង់ហ្វ៊ា ផ្សារមាស ថ្វឹងសំណ ហូតលួស ។

ហាត់ភាសា — ក្រៅអំពីធាតុឈើនឹងធាតុថ្ម មានធាតុអ្វីទៀត? អ្វីខ្លះដែលរាប់បញ្ចូលក្នុងពួកធាតុដែក ?

ធាតុដែកអ្វីដែលមានដម្លៃជាងគេ ? ព្រោះអ្វី ? ឯដែកមានប្រយោជន៍ឬទេ ? ព្រោះអ្វី ? អ្នកបានឃើញគេយកប្រាក់នឹងមាសទៅធ្វើជាវត្ថុអ្វីខ្លះ ។

ការហាត់សរសេរ — ចូររើសយកពាក្យខាងក្រោមនេះដាក់បំពេញឃ្លាទៅក្នុងចន្លោះពងត្រី ៖ ដែក - ស្ពាន់ ទង់ដែង មាស - ប្រាក់ សំណ រឹង ទន់ ម៉ាំ ក្រហមឆ្អៅ ៖

មនុស្សយើងត្រូវការ .......(ដែក) យកមកធ្វើជាគ្រឿងប្រើប្រាស់គ្រប់ជំពូក ព្រោះជាជាតិ .......(រឹង) ហើយ .....(ម៉ាំ) ផង ឯស្រី ៗស្រឡាញ់តែ .......(មាស - ប្រាក់ - ទង់ដែង) យកមកធ្វើជារូបិយវត្ថុសំរាប់ពាយ ។

នៅប្រទេសបារាំងកំពដការបង្កើតឲ្យមានរូបិយវត្ថុដែលមានដម្លៃបំផុតធ្វើ .......(មាស) ឯ ........(សំណ) គេយកមកធ្វើជាបំពង់ទឹក ព្រោះជារបស់ ......(ទន់) ស្រួលពត់បត់បែនបុះឡើងបាន ។

## អំពីជាងដែក

នាម – ជើងក្រាន ស្នប់ ទ្រនាប់ ដង្កាប់ ត្បូង ចុងសំលៀង ពាងទឹក ស្នាប ជើងម៉ា ដែក កាំបិត ពូថៅ ចប ប៉ែល ។

គុណនាម – សន្ធោសន្ធៅ ស្រអាប់ ជ្រាយ រឹង កោង ត្រង់ មុត ។

កិរិយាសព្ទ – សប់ភ្លើង ដុតដែក កាត់ដែក ច្រូងកាំបិត ផ្គុំពូថៅ សំលៀងចប លត់ពន្លាក់ ។

វិធីហាត់ភាសានិងហាត់សរសេរ – សុំឲ្យធ្វើដូចរបៀបមុន ។

## បង្រៀនមើល

១ - អំពីដែក (សៀវភៅវត្ថុស្វាធ្យាយទំពរប្រណាដ្ឋាន ទំព័រ៨៨) ។

២– អំពីលោហធាតុ – ជាតិដែក – ជាតិស្ពាន់ស – ជាតិទង់ (សៀវភៅវត្ថុស្វាធ្យាយ ភាគកណ្ដាលទំព័រ ១២៧) ។

**សរសេរតាមសូត្រ**

## អំពីលាយលោហធាតុ

អស់ចាំងលោហធាតុដែលនៅក្នុងដីចាំងប៉ុន្មាន ដូនណាសុខ

ផ្ដនណាលាយនឹងធាតុឯទៀត  តាមធម្មតាលោហធាតុសុទ្ធពុំសូវប្រើការតែឯងទេ  គេត្រូវយកមកលាយនឹងធាតុឯទៀត ទើបប្រើការបាន ។

ឯលោហធាតុដែលគេប្រើការក្នុងគ្រឿងដែកនោះ  គឺស្ពាន់ស័ង្កសី សំណនឹងសំណប៉ាហាំង ។ ស្ពាន់ជាលោហធាតុពណ៌ក្រហម  កាលណាត្រូវទឹកម្ជូរឬទឹកខ្ទះទៅមានច្រេះបាច់  ឯច្រេះនេះជាថ្នាំពុលពូកែណាស់ ហេតុនេះត្រូវផុសលាងសំអាតឆ្នាំងស្ពាន់ឬវែកស្ពាន់  ដែលប្រើការក្នុងផ្ទះបាយឲ្យស្អាតជានិច្ច  ដើម្បីកុំឲ្យមានច្រេះឬដុះស្នឹម ។

ស័ង្កសីជាធាតុមានពណ៌សខៀវ ( ពណ៌ប្រផេះ ) សម្រាប់ធ្វើជាប៉ោតដងទឹក  ប៉ោតស្រោចដំណាំ  សុកឡូតទឹក  ទបង្ហូរទឹក ហើយនឹងប្រក់ផ្ទះ  គេយកដែកមកលាយនឹងធាតុនេះ  ដើម្បីកុំឲ្យច្រេះបាច់ ។

សំណប៉ាហាំងជាធាតុស  គេកិនធ្វើជាស្លឹកស្ដើង ៗ បាន គេហៅជាស្លឹកសំណប៉ាហាំង  សំរាប់ខ្ចប់ចំណីអាហារ ។

អក្ខរាវិរុទ្ធ — សុទ្ធ — ឯកឯង — ទឹកម្ជូរ — ផុសលាង -- ដុះស្នឹម ទបង្ហូរទឹក ។

## តែងសេចក្ដី

ចូរអធិប្បាយអំពីធាតុដែក  តាមពាក្យចោទខាងក្រោមនេះ  របស់

អ្វីខ្លះ ដែលចូលមកក្នុងពួកធាតុដែក (លោហធាតុ), ធាតុដែកកើតមកពីអ្វី, ពណ៌យ៉ាងដូចម្ដេចខ្លះ, គេឃើញមាននៅឯណា, គេធ្វើដូចម្ដេចខ្លះ ទើបបានរបស់នោះយកមកប្រើការគ្រប់ជំពូក, អ្នកចូលចិត្តរប់អានធាតុដែកឬទេ, ព្រោះអ្វី? ។

## អក្សរផ្ចង់

ង ផ ដ ជ ដេដើដេង ដោង ជួជក់ងងុយដេក

ដើរផុំងដកដង្ហើមផើតផិត ។

## រៀនពាក្យហាត់ភាសា

### អាទិត្យទី ២ – អំពីផលប្រយោជន៍ដែក

នាម= កាំបិត ដឹង ពូថៅ រណារ ពន្លាក ដែកស្វាន ដែកគោល ដែកខ្វង ញញួរ ដង្កាប់ គ្រីប ចប ប៉ែល ផាល ម៉ាស៊ីន កថ៉ាល រថយន្ត យន្តហោះ ប្រដាក់ យុថ្កា ស្ពាន ។ ល ។

គុណនាម– មុត រិល ធែប ស្រួច ទាល មូល សំប៉ែត តូច

ធ្មារ មាំ ស្អិត យឺត គោង ត្រង់ ។

កិរិយាសព្ទ– ពត់មុខរណារ ឆាបរណារ អារឈើ ពុះឧស សំលៀងពន្លាក វាយដែកគោល ដាក់ដងកាំបិត ឈូសឈើ ដកដែកគោល ដំដែក ដោះយុថ្កា ។ល។

ហាត់ភាសា របស់អ្វីខ្លះ ដែលធ្វើអំពីដែក ? នៅផ្ទះអ្នកមានប្រដាប់ប្រើប្រាស់អ្វីខ្លះ ដែលធ្វើអំពីដែក ? កាំបិតសម្រាប់ប្រើការអ្វី ? ពូថៅ ពន្លាក - រណារ - ដឹង ។ល។ សម្រាប់ប្រើការអ្វី ? ។

ការហាត់សរសេរ ចូរតែងជាឃ្លានឹងពាក្យខាងក្រោមនេះ ៖ កាំបិត - រណារ - ពន្លាក - ដែកគោល - ញញួរ

## ២ អំពីផលប្រយោជន៍ស្ពាន់

នាម រូបយន្ត គ្រឿងម៉ាស៊ីន គ្រឿងអលង្ការ ខ្សែលួស នាឡិកា ថ្នាំងខ្ទះ ថ្នាំងអុត ស្លាបព្រា សម កណ្ដឹង គង រគាំង ជួង បង្កើង ព្រះពុទ្ធរូប រូបផ្សេង ៗ ប្រអប់ អកកំបោរ ហិបស្លា សោហិប ត្រចៀកហិប គោមចង្កៀង កន្ទោរ ។ល។

គុណនាម– ក្រហម ស ខ្មៅ ភ្លឺ ស្រអាប់ រឹងមាំ អាក្រក់ ពៀច ប៉ោង ទ្រុត ។

កិរិយាសព្ទ– រំលាយស្ពាន់ សិតរូបផ្សេង ៗ ខាតជួង- ដុតតុ

ដាក់ត្រចៀកហិប ប្រអប់ ។

ហាត់ភាសានិងហាត់សរសេរ ( សូមធ្វើដូចមុន )

## បង្រៀនមើល

១- សំណ ស្ពាន់ ស្ពាន់លឿង

( សៀវភៅវត្ថុស្វាធ្យាយន៍បរិច្ឆណដ្ឋានទំព័រ៩៣មេរៀនទី១១ )

២- អំពីលោហធាតុ ជាងដែក ជាងស្ពាន់ ជាងទង

សៀវភៅវត្ថុស្វាធ្យាយន៍អាទិកដ្ឋានទំព័រ១២៦ ) ។

សុំឲ្យកែតម្រូវពាក្យខុះដូចខាងក្រោមនេះ ៖

ទី ១ កំបិត កាំបិត ។ ដុះ ដុស (ដុសឲ្យស្អាត) អំពង់ បំពង់ ប្រយាត់ ប្រយ័ត្ន ។

ទី ២ បង្ក្រាន ជើងក្រាន ។ សរ ស (សក្បុស) សង្កសី ស័ង្កសី ។

## តែងសេចក្ដី

ចូរអធិប្បាយអំពី ផលប្រយោជន៍ដែកតាមពាក្យចោទ ខាងក្រោមនេះ៖

ស្រុកខ្មែរយើងគេយកដែកពីកន្លែងណាមក អ្នកឃើញគេយកដែក

មកប្រើការដូចម្ដេចខ្លះ? អ្នកចូលចិត្តពាក់អាវដែកឬទេ? ព្រោះអ្វី?

២– ចូរអ្នកអធិប្បាយអំពីជាងដែកតាមពាក្យចោទខាងក្រោមនេះ ៖

នៅក្នុងភូមិអ្នកមានជាងដែកឬទេ? ជាងនោះជាតិអ្វី? រោងជាងនោះនៅត្រង់ណា? នៅក្នុងនោះមានរបស់អ្វីខ្លះ? មានមនុស្សធ្វើការច្រើនឬតិច? ក្នុងមួយថ្ងៃៗអ្នកឮសូរដូចម្ដេច នៅក្នុងរោងនោះ ជាងដែកមានប្រយោជន៍ទឹងយើងឬទេ? ព្រោះអ្វី? អ្នកចូលចិត្តជាងដែកនោះឬទេ? ព្រោះអ្វី? ។

## អក្សរផ្ចង់

ង ងឹ ងិ ង ឯ ង្ហូរងង់ ងីងុះ ងុសកណ្ដាលទន្លេ

ង្ហូតទឹកងុសង្ហូតងីរះឡើងជ្រុះស្លឹកល

ទៅឯណា ទៅឯណោះ ។

## បង្រៀនពាក្យ ភាសា

### អាទិត្យទី ៣– ១ អំពីផលប្រយោជន៍ប្រាក់

នាម – រូបិយវត្ថុ ( ប្រាក់រៀល ប្រាក់កាក់ ) កង់ជើង កង់ក កា

ចិញ្ចៀន ខ្សែក្រវាត់ ខ្សែនាឡិកា ហិបស្លា ជើងពាន តុ វែក ផ្តិល ។ល។

គុណនាម – សផ្លាវ រលីង ម៉ដ្ឋ គគ្រាត គគ្រើម ទន់ រឹង

កិរិយាសព្ទ – រំលាយប្រាក់ ធ្វាក់ក្បាច់ ហូតលួសប្រាក់ ស្អាក់ព្រះពុទ្ធរូប វាតកង់ជើង ធ្វើការ ខ្សែក្រវាក់ ។

## ២– អំពីជាងទង

នាម – អង្គំ តុ ពពាយ មេដែក ចង្កៀងខ្វញ់ ជើងតាំង ជង្កាប់ ដំបៀត ដែកឆ្កេះ ដែកក្រចក ដែកខែ ដែកឆាប ក្រដាស់ខាត់ ថាស តម្រង ច្រាស បំពង់ ។

គុណនាម – ក្រហមឆ្អៅ ភ្លឺផ្លេក ប្រសប់រហ័ស រហូន ហ្មត់ចត់ ស្អាត ពូកែ ទៀយ ធ្ងន់ ស្រាល រួយ ស្រពន់ ស្គម

កិរិយាសព្ទ – ខាត់ កង់ដៃ ពោសកំទេចមាស ដាំត្បូង ឲ្យដី មាស ឆាបទង់ទំហ៊ូ ។ល។

## ៣.– អំពីផលប្រយោជន៍មាស

នាម – ទំហូ កន្ទាស់ក ខ្សែដៃ ខ្សែខ្លួន ខ្សែក ស្នៀ សក់ ចិញ្ចៀន ខ្សែនាលិកា ។ល។

គុណនាម – ទន្លាលច្រាលឆ្អៅ វែង ខ្លី រលោង រលើប ភ្លឺស្រា អាប់ ស៊ក ពៀច វៀច ត្រង់ ។

កិរិយាសព្ទ - ធ្វើបិញ្ញៀន ឆាបកន្ទាស់ក ស្អាងព្រះពុទ្ធរូប ក្លាប់ ក្បាច់ស្លៀតសក់ ។

## ៤- អំពីផលប្រយោជន៍សំរិទ្ធ

នាម - គង់ រគាំង ផ្តិល ត្បាល់បុកស្លា ពពិល ប្រអប់ ក្លង សីមា បង្គ្រន់ កណ្ដឹង ។

គុណនាម - រលើង រលើប ខ្មៅព្រីក ប្រហោង តាន់ ធ្ងន់

កិរិយាសព្ទ.- រំលាយសំរិទ្ធ សិតគង់ រគាំង បង្គ្រន់ កណ្ដឹង ខាត់ ត្បាល់បុកស្លា ឆ្លាក់ក្បាច់ពពិល ។

## បង្រៀនមើល

## ១- អំពីប្រាក់-មាស

សៀវភៅវគ្គស្វាធ្យាយបរិច្ចេណដ្ឋានទំព័រ ៩៥ សុំឲ្យកែតម្រូវពាក្យៈ ខ្សែករ = ខ្សែក ។ ពណ៌សរ ( ស ) វេច្ចណា = ចេនា ( ៖ច;នា″ )

## ២- អំពីជាងស្មិត

សៀវភៅវគ្គស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ១២៩ ។

# សរសេរតាមសូត្រ

## ១- អំពីប្រាក់ - នឹងមាស

ប្រាក់នឹងមាសជាលោហធាតុមានដម្លៃច្រើន ជាងលោហធាតុឯទៀត ប្រាក់មានសម្បុរស មានដម្លៃបន្ទាប់ពីមាសមក គេធ្វើជារបស់សម្រាប់តាយនឹងប្រកបការរចនាបានច្រើនយ៉ាង ប៉ុន្តែត្រូវលាយស្ពាន់បន្តិចផង ដើម្បីឲ្យរឹង ។

មាសជាធាតុបរិសុទ្ធ មានសាច់ទន់ស្វិតសម្បុរលឿង សម្រាប់ប្រើការធ្វើជាគ្រឿងប្រដាប់កាយ នឹងការរចនាវិចិត្រផ្សេង ៗ ប្តីជួនកាលប្រទេសខ្លះប្រើជារបស់តាយជំនួសប្រាក់ក៏មាន គេយកមាសទៅប្រើការសុទ្ធតែឯងពុំបានទេ ព្រោះជារបស់ទន់ហើយឆាប់សឹកដូចប្រាក់ដែរ ហេតុដូច្នេះបានជាគេលាយនឹងស្ពាន់បន្តិច ប៉ុន្តែត្រូវទុកឲ្យគង់សម្បុរជាមាសដពប ។

អត្ថពីរុទ្ធ - លោហធាតុ - សម្បុរស . ការរចនា . វិចិត្រ បរិសុទ្ធ ជំនួស . សឹក ។

## ២- អំពីការជាងស្មិត

ជាងស្មិតផុតលោហធាតុឲ្យរលាយទៅជាវត្ថុរាវ ហើយបង្ហូរទៅក្នុង

ពុម្ពមួយ ដើម្បីឲ្យមានទ្រង់ទ្រាយតាមពុម្ពនោះ ជារបស់ផ្សេង ៗ ដល់កាលណាត្រជាក់ទៅ ៗ គេយកដែកស្វិត គឺដែកដែលលាយនឹងធ្យូង ស្ពាន់ - សំណ - ស័ង្កសីទុកសម្រាប់ប្រើការ ៗ

អ្នកស្រុកអាយពុំសូវប្រើដែកស្វិតទេ ៗ នៅប្រទេសឥណ្ឌូចិនមានគ្រឿងស្វិតរបស់បារាំងសម្រាប់បង្កើតដែកស្វិត បំរុងទុកធ្វើវត្ថុផ្សេង ៗ ដូចជាឆ្នាំងខ្ទះ ឆ្នាំងបាយ ៗល ៗ

អក្ខរាវិរុទ្ធ: វត្ថុរាវ បណ្ហូរ ពុម្ព ទ្រង់ទ្រាយ ធ្យូង ស័ង្កសី ៗ

## តែងសេចក្ដី

១ ចូរអ្នកអធិប្បាយអំពីជាងទង់នៅភូមិអ្នក តាមពាក្យចោទខាងក្រោមនេះ ៖

នៅក្នុងភូមិអ្នកមានជាងទង់ឬទេ? ជាងនោះជាតិអ្វី ? ឈ្មោះអ្វី? ផ្ទះជាងនោះនៅត្រង់ណា ? នៅក្នុងផ្ទះជាងនោះអ្នកឃើញរបស់អ្វីខ្លះ? មនុស្សធ្វើការច្រើនឬតិច ? ក្នុងមួយថ្ងៃ ៗ អ្នកឮសូរដូចម្ដេចក្នុងផ្ទះជាងនោះ? អ្នកឃើញគេដាក់គ្រឿងអលង្ការនៅក្នុងអ្វី? ជាងទង់មានប្រយោជន៍ដល់អ្នកទាំងពួងឬទេ? ព្រោះអ្វី? អ្នកចូលចិត្តធ្វើជាងទង់ឬទេ? ព្រោះអ្វី? ៗ

២–ចូរអ្នកអធិប្បាយអំពីអ្នកដឹងដូចម្ដេចខ្លះ អំពីគេប្លន់អំបិល តាមអ្នកបានឮគេនិយាយក្ដី តាមអ្នកបានឃើញក្ដី ?

ចំណងតែងនិងគំរូសេចក្ដីនៃសេចក្ដីទី ២ , សូមមើលក្នុងទស្សនាវដ្ដី ឆ្នាំទី ៣ លេខ១៨ទំព័រ២៧ ។

អធិកាដ្ឋាន

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ១ អំពីពេលវេលា

នាម: ថ្ងៃ យប់ អាទិត្យ ខែ ឆ្នាំ មួយរំពេច មួយស្របក់ ម៉ោង នាទី ( មីនុត ) វិនាទី ( សឺកុង )

គុណនាម: ក្ដី ធំដិត យូរ ឆាប់ រហ័ស យឺត ឆ្នាំចាស់ ឆ្នាំថ្មី ខែមុន ខែក្រោយ ដើមខែ ចុងខែ ។

កិរិយាសព្ទ: ចែកពេលវេលា កត់ខែ ថ្ងៃ ឆ្នាំ រាប់ថ្ងៃ ខែ ឆ្នាំ មើលម៉ោង នាទី ថ្ងៃរះ ថ្ងៃលិច ។

ហាត់ភាសា– ដែលហៅថាពេលវេលានោះ គឺអ្វី? ក្នុង១ឆ្នាំមានប៉ុន្មានខែ? គឺខែអ្វីខ្លះ? ខ្មែរយើងរាប់ឆ្នាំជាប៉ុន្មាន? គឺឆ្នាំអ្វីខ្លះ? ក្នុងមួយខែមានប៉ុន្មានថ្ងៃ ។

ក្នុងមួយអាទិត្យមានប៉ុន្មានថ្ងៃ ; គឺថ្ងៃអ្វីខ្លះ , ក្នុងមួយថ្ងៃ មួយយប់ មានប៉ុន្មានម៉ោង ? ។

## បង្រៀនមើល

### អំពីពេលតាមរបៀបខ្មែរ

( សៀវភៅវត្តស្វាធ្យាយន៍បរិច្ឆណដ្ឋានទំព័រ ១០៨ ) កែតម្រូវ អាសុឍ=អស្សុជ ។ បឋមសាធ=បឋមាសាធ ។

## សរសេរតាមសូត្រ

### ពេលវេលា

ដែលហៅថាពេលវេលានោះ គឺគេសម្រេចយកតាមកំណត់ដំណើរព្រះធរណីវិលជុំវិញខ្លួនឯង ហើយនឹងវិលក្រឡឹងជុំវិញព្រះអាទិត្យផង ។ ពេលដែលព្រះធរណីវិលបានមួយជុំខ្លួនឯងនោះ ហៅថាមួយថ្ងៃមួយយប់ គឺម្ភៃបួនម៉ោង លុះព្រះធរណីវិលបានមួយជុំព្រះអាទិត្យ ទើបហៅថាមួយឆ្នាំ ។ មួយឆ្នាំមានបីរយហុកសិបប្រាំថ្ងៃ ឬ ហាសិបពីអាទិត្យ ។

ដែលហៅថារដូវនោះ គឺក្នុងកំឡុង ដែលខ្យល់អាកាសផ្លាស់ប្តូរក្នុង ១ ឆ្នាំៗ ។

អក្ខរាវិរុទ្ធ— ដំណើរ – ព្រះធរណី - ព្រះអាទិត្យ . ខ្ពុ – ហុកសិប ប្រាំ - ហាសិបពីរ – ខ្យល់ផ្លាស់ប្ដូរ ។

## តែងសេចក្ដី

ចូរអធិប្បាយអំពីអ្នកប្រើពេលវេលាដូចម្ដេច តាំងពីព្រលឹមរហូតដល់ព្រលប់ ។

## ទំនងតែង

តាំងពីព្រលឹមរហូតដល់ពេលបាយ អ្នកធ្វើអ្វីខ្លះ ? ចុះពេលល្ងាច ទល់នឹងព្រលប់អ្នកធ្វើអ្វីទៀត? ។

## អក្សរផ្ចង់

បង្រៀនសរសេរអក្សរ មូលឈុ ១៥ ។

អាទិត្យទី២–

នាម.– ខ្យល់ ខ្យល់រំភើយ ខ្យល់ដំណោរ ខ្យល់ព្យុះ ព្យុះសង្ឃរា ខ្យល់កំបុតត្បូង (ខ្យល់គួច) ខ្យល់ពីទិសឯជើង ។

គុណនាម.– រហើយត្រសៀក ត្រជាក់រងាតិច ខ្លាំងវក់វី ខ្លាំងអស្ចារ្យ ។

កិរិយាសព្ទ.— ខ្យល់បក់តិចៗ ខ្យល់បក់ខ្លាំង ខ្យល់គួចធូលី ខ្យល់រំលំរលើងដើមឈើ បង្ហើរខ្ទង់ បើកក្តោង ។

## បង្រៀនមើល

### ខ្យល់បក់ពីទិសខាងជើង

(សៀវភៅខេមរភាសាបរិច្ឆណាផ្ទួនទំព័រ ៦៤)

## សរសេរតាមសូត្រ

### អំពីខ្យល់

កាលណាយើងឈរឬអង្គុយនៅកណ្ដាលទីវាល ហាក់ដូចជាមានធម្មជាតិអ្វីមកប៉ះពាល់ខ្លួនយើងឲ្យស្រ្ហើយ ធម្មជាតិនេះហៅថាខ្យល់ ឯបឹកដែលកំរើកទៅមកបាននោះគឺខ្យល់បក់ ។ ខ្យល់បក់នេះជួនខ្លាំងជួនតិច ខ្យល់បក់តិចៗហៅថាខ្យល់ជំនោរ ខ្យល់បក់ខ្លាំងហៅថាព្យុះ ។ កាលណាខ្យល់នោះបក់ខ្លាំងអស្ចារ្យ ហៅថាព្យុះសង្ឃរា ។

ខ្យល់ព្យុះអាចធ្វើឲ្យដើមឈើ ផ្ទះសម្បែង ទូក កប៉ាល់វិនាសអន្តរាយៈភ្ជន ។

ខ្យល់មានប្រយោជន៍ ដើម្បីឲ្យអ្នកដើរទូកសំពៅបើកក្តោងលឿនទៅ បានដោយងាយ ។

អក្ខរាវិរុទ្ធ — ធម្មជាតិ-ខ្យល់-ល្ហើយ-រាល-ព្យុះសង្ឃរា-វិនាស-អន្តរាយ អស្ចារ្យ- កញ៉ាល់- លឿន ។

## តែងសេចក្តី

ចូរអធិប្បាយអំពីខ្យល់ព្យុះតាមពាក្យចោទខាងក្រោមនេះ

យ៉ាងដូចម្តេចដែលហៅថាខ្យល់ព្យុះ ? នៅក្នុងរដូវណាដែលច្រើន មានខ្យល់ព្យុះ ? ខ្យល់នោះបក់មកពីទិសខាងណា ? មុននឹងមានខ្យល់នោះ អ្នកសំគាល់ឃើញមានអ្វីនៅជើងមេឃ ?

វេលាខ្យល់បក់មកអ្នកព្រួសរដូចម្តេច ?/ អ្នកឃើញមានអ្វីមកជាមួយផង ? ខ្យល់នោះបណ្តាលឲ្យមានហេតុដូចម្តេចខ្លះ? នៅក្នុងភូមិអ្នកនៅក្នុងទន្លេ ។ អ្នកចូលចិត្តនឹងខ្យល់នោះឬទេ? -ព្រោះអ្វី? ។

## បង្រៀនពាក្យ នឹង ភាសា

អាទិត្យទី៣— អំពីភ្លៀង

នាមៈ ភ្លៀង ផ្គរ រន្ទះ ផ្លេកបន្ទោរ ឥន្ទធនូ សន្សើម គ្រាប់ភ្លៀង ទឹកភ្លៀង ។

គុណនាម– ច្រើន តិច ស្រប់ៗ ប្រយៗ ទទឹក ជោក សើម ។

កិរិយា– រាំងភ្លៀង ភ្លៀងស្រក់តក់ៗ ទឹកភ្លៀងជ្រាបទៅក្នុងដី ត្រងទឹកភ្លៀង ផ្លូតទឹកភ្លៀង ជូតខ្លួន ។

## អំពីនាឡិកា

នាម– នាឡិកាយោល នាឡិកាពក់ នាឡិកាដក់ ផ្ទះនាឡិកា គ្រឿងនាឡិកា ខ្សែឡាន កូនសោ ប៉ោល ទ្រនិច លេខ កញ្ចក់ យ៉ៃ ។

គុណនាម– ទៀង យឺត គាំង ខូច ដាច់ឡាន ថ្មី ចាស់ ។

កិរិយា– មួលនាឡិកា ផ្ទៀងនាឡិកាប្តូរម៉ោង បង្វិលទ្រនិច មើលម៉ោង..............។

## សរសេរតាមសូត្រ

## អំពីភ្លៀង

ទឹកភ្លៀងកើតមកអំពីពពក ឯពពកកើតឡើងអំពីចំហាយទឹកនៅវេលាដែលត្រូវកំដៅព្រះអាទិត្យ ប្រមូលផ្តុំគ្នាឡើងហើយអណ្តែតទៅពេញអាកាស កាលណាពពកនោះរសាត់ទៅប្រទះនឹងខ្យល់ត្រជាក់ខ្លាំងក៏កកទៅជាទឹក ហើយធ្លាក់មកជាភ្លៀង ទឹកភ្លៀងជ្រាបទៅក្នុងដីសម្រាប់ចិញ្ចឹមរុក្ខ-

ជាតិទាំងឡាយ ប្រមូលផ្ដុំគ្នាកើតបានជាដង្ហើមទឹក មួយចំណែកទៀតហូរធ្លាក់ទៅក្នុងថ្លុកត្រពាំង បឹង ស្ទឹង ទន្លេ សមុទ្រ ។

កាលណាមានភ្លៀងច្រើន តែងមានព្យុះផ្គរ ផ្លេកបន្ទោរ ហើយនឹងរន្ទះផង ។

អក្ខរាវិរុទ្ធ — ភ្លៀងផ្ដៀង- ផ្ដុំ- អណ្ដែត- រសាត់- រុក្ខជាតិ- ព្យុះ-ផ្គរ ផ្លេកបន្ទោរ- ។

## តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីថ្ងៃមួយដែលមានភ្លៀងមួយមេយ៉ាងធំ ។ អ្នកបានឃើញដូចម្ដេចខ្លះ នៅវេលាមុនភ្លៀង វេលាកំពុងភ្លៀង វេលាក្រោយភ្លៀង ? យោបល់របស់អ្នកយល់ឃើញដូចម្ដេចអំពីភ្លៀងនេះ ? ។

---

កុមារដ្ឋាន

## បង្រៀនពាក្យ និង ភាសា

### អាទិត្យទី ១ — អំពីភូមិ

នាម — ភូមិ, ក្រុង, ផ្លូវ, ផ្ទះ, សាលារៀន, សាលាឃុំ, ទន្លេ, ព្រែក, បឹង,

របង, ទ្រុងជ្រូក, ក្រោលគោក្របី, ដើមឈើ, ដំណាំ, ចេក, ត្របែក, ក្រូច, ម្នាស់, ខ្នុរ, ស្វាយ, ដូង, ស្វា, ត្នោត, អំពិល, កន្ទួត, សណ្ដាន់, ក្រសាំង, ខ្ទិត, វាលស្រែចំការ ៗ

គុណនាម– ឆ្ងាយ, ជិត, ធំ, ទូលាយ, ខ្ពស់, ទាប, ស្អាត, កខ្វក់, ច្រើន, តិច, ស្អុយ, ស្អុះ, ផ្អែះ, ឆ្អាប, ៗ

កិរិយាសព្ទ– ដើរកាត់ទៅភូមិ, ចូលក្នុងក្រុងធំ, ចេញពីភូមិ, សង់ផ្ទះ, ដាំចេក, បោសសំអាតភូមិ, កាប់ឈើ, ធ្វើក្រោលក្របី, រុះរើទ្រុងជ្រូក, ចាក់ដីពេញថ្លុក, បុកពង្រាបដីភូមិ, ៗ

ភាសា– ភូមិអ្នកឈ្មោះអ្វី? ភូមិនោះខាងណាទីក្រុង? ឆ្ងាយឬជិត? ភូមិនោះធំឬតូច? បង្អៀតឬទូលាយ? នៅភូមិនោះមានផ្ទះច្រើនឬតិច? ផ្ទះសង់ខ្ពស់ឬទាប? ដំបូលប្រក់អ្វី? ផ្ទះអ្នកនៅឆ្ងាយឬជិតសាលាឃុំ? នៅភូមិអ្នកមានសាលារៀនឬទេ? មានដើមឈើនិងដំណាំអ្វីខ្លះនៅក្នុងភូមិអ្នក ?

## អាទិត្យទី២– អំពីវត្ត

នាម– ទីធ្លា, កំពែង, របង, ខ្លោងទ្វារ, ផ្លូវធ្លា, ដើមឈើ, ព្រះវិហារ, កុដិ, សាលា, ព្រះចេតិយ, កំពូល, ខ្ទមអ្នកតា, រោងទូកង, រានទេវតា, អាស្រម, ផ្ទះដូនជី, ក្បាច់ចេនា, ដើមផ្កា, ព្រះពុទ្ធរូប, លោកសង្ឃ, ឧបាសក, ទាយក ៗ

គុណនាម– ស្អាត, ល្អ, ធំ, ទូលាយ, រលីប, ខ្ពស់, ទាប, ពងស្វី,

ស្រងប់, រុងរឿង, ថ្កុំថ្កើង, រន្ទាលប្រាលឆ្អៅ, ឆ្ងាយ, ជិត, ត្រសាយ, ក្រអូប, ឈ្ងួយឈ្ងប់, ទ្រហឹងអឺងកង, ស្ងាត់ឈឹង ។

កិរិយាសព្ទ — សង់, កសាង, បូជាធម្ម, សូត្រធម្ម, ស្វាធ្យាយបាលី ។ ដាក់បាត្របុកបាត្រ និមន្តលោកឆាន់, សូត្រមន្ត ។

ភាសា — ភូមិអ្នកមានវត្តឬទេ? ឈ្មោះអ្វី? វត្តនោះសង់នៅត្រង់ណាភូមិអ្នក? (កណ្តាលឬចុងភូមិខាងណា) មានអ្វីព័ទ្ធជុំវិញ? ព្រះវិហារសង់អំពីអ្វី? បែរមុខទៅខាងណា? សង់លើអ្វី? នៅខាងមុខព្រះវិហារមានអ្វីខ្លះ? កុដិលោកគ្រូចៅអធិការសង់នៅទីណា? មានកុដិឯទៀតច្រើនឬតិច? ចំនួនប៉ុន្មាន? នៅក្នុងទីធ្លាមានដាំដើមផ្កាឬទេ? ប្រយោជន៍អ្វី?

ថ្ងៃណាដែលមានមនុស្សច្រើនជាងគេនៅទីវត្ត? ពួកឧបាសកទៅកាន់ទីវត្តដើម្បីធ្វើអ្វី? ប្រយោជន៍អ្វី? អ្នកចូលចិត្តទៅវត្តឬទេ? ហេតុអ្វី?

## អាទិត្យទី ៣ ថ្ងៃទី ៤ — អំពីក្រុង

នាម — ផ្សារ, ផ្លូវថ្នល់, ទន្លេ, ព្រែក, ស្ពាន, ថ្នុក, ត្រពាំង, ផ្ទះផ្សារ, ផ្ទះលក់ទំនិញ, គេហស្ថាន, វត្តលោក, វាំង, សាលារៀន រោងមាស៊ីន, រោងជាងទង, ជាងដែក, ជាងឈើ, សាលារចនា, ចង្កៀង, គោមអគ្គិសនី, យានជំនិះផ្សេងៗ ជនានុជន, ប្រដាប់ស្លៀកពាក់ ប្រដាប់ប្រើប្រាស ។

គុណនាម– រុងរឿង, ថ្កុំថ្កើង, ល្អ; អាក្រក់, ស្អាត, កខ្វក់, ធំទូលាយ, ខ្ពស់, ស្រឡះ, សម្បើម, មាំ, ស្រួប, វែង, សុខក្សេមក្សាន្ត, ជិត; ឆ្ងាយ, ក្រហេងក្រហូង, រាប់ស្មើ, ច្រើនពោរពាសខ្វាត់ខ្វែង, ឈូរង, ទ្រហឹងអឺងកង, បង្អៀតគាន់គាប់, រំពាទ៍ខ្ទរខ្ទា, គឹកគ្រេង ៗ

កិរិយា– រៀបចំទីក្រុង, ចាក់ដី, លុបថ្កុកត្រពាំង, យកខ្សាច់, កិនគ្រួស, ធ្វើស្ពាន, សង់ផ្ទះ, ដើរលេងផ្សារ, លក់ទំនិញ, ទៅទិញសំពត់, ជិះរទេះ, ឆ្លងកាត់ព្រែក, ចូលក្នុងផ្សារ, ដើរត្រួតត្រា, ឈរយាមល្បាត, បោសថ្នល់, កើបសំរាម, បង្ហូរទឹកសំអុយ ៗ

---

បរិវត្តណាដ្ឋាន

## បង្រៀនពាក្យ និង ភាសា

### អាទិត្យទី ១– អំពីពេលវេលា.

នាម– ថ្ងៃ, យប់, អាទិត្យ, ខែ, ឆ្នាំ, មួយរំពេច, មួយស្របក់, ម៉ោង, នាទី ( មីនុត ) វិនាទី ( សឺកុង ) ៗ

គុណនាម – ភ្លឺ, ងងឹត, យូរ, ឆាប់, ឆ្នាំ; ចាស់, ឆ្នាំថ្មី, ខែមុន ខែក្រោយ; ដើមខែ, ចុងខែ កណ្ដាលខែ ៗ

កិរិយាសព្ទ - ខាតពេលវេលា , កត់ថ្ងៃខែឆ្នាំ , មើលម៉ោង , ថ្ងៃរះ ថ្ងៃលិច , ថ្ងៃចាំង ។

ភាសា - ដែលគេហៅថាពេលវេលានោះគឺអ្វី ? ក្នុងមួយឆ្នាំមានប៉ុន្មានខែ ? គឺខែអ្វីខ្លះ ? ឯឆ្នាំគឺឆ្នាំអ្វីខ្លះ ? ក្នុងមួយអាទិត្យមានប៉ុន្មានថ្ងៃ ? គឺថ្ងៃអ្វីខ្លះ ? ក្នុងមួយខែមានប៉ុន្មានថ្ងៃ ? ក្នុងមួយថ្ងៃមួយយប់មានប៉ុន្មានម៉ោង ?

## អាទិត្យទី ២- អំពីខ្យល់

នាម ខ្យល់ , ខ្យល់រំភើយ , ខ្យល់ដំនោរ , ខ្យល់ព្យុះ , ខ្យល់សង្ឃ្យា , ខ្យល់កំបុតត្បូង ( ខ្យល់គួច ) ខ្យល់ពីងដើង ។

គុណនាម - រហើយត្រសៀក , ត្រជាក់ , រងារ , តិចខ្លាំង វក់វី ។

កិរិយា - ខ្យល់បក់តិច ៗ ខ្យល់បក់ខ្លាំង , ខ្យល់គួចធូលី , បង្ហើរខ្លែង , បើកក្ដោង ។

## អាទិត្យទី ៣ - អំពីភ្លៀង - ឥន្ទធនូ

នាម - ភ្លៀង , ផ្គរ , រន្ទះ , ផ្លេកបន្ទោរ , ឥន្ទធនូ , សន្សើម , គ្រាប់ភ្លៀង , ទឹកភ្លៀង ។

គុណនាម - ច្រើន , តិច , ស្រិច ៗ ប្រុយ ៗ ; រលឹម , ទទឹកជោក សើម ។

កិរិយា – រាំងភ្លៀង , ភ្លៀងស្រក់តក់ ៗ, ទឹកភ្លៀងជក់, ទឹកភ្លៀងជ្រាបទៅក្នុងដី, ត្រងទឹកភ្លៀង, ងូតទឹកភ្លៀង ៗ

## អាទិត្យទី ៤ – អំពីនាឡិកា

នាម – នាឡិកាឬនាលិកា , នាលិកាយោល , នាលិកាពេទ , នាលិកាដក់, ផ្ទះនាលិកា, គ្រឿងនាឡិកា, ខ្សៅឡាន, កូនសោប៉ោល, ទ្រនិច , លេខ , កញ្ចក់ , យ៉ៃ ៗ

គុណនាម – ទៀង , យឺត , លឿន , គាំង , ខូច , ដាច់ឡាន , ថ្មី ចាស់ ៗ

កិរិយា – មួលនាឡិកា , ផ្សៀងនាលិកាឬម៉ោង , បង្វិលទ្រនិច មើលម៉ោង , នាលិកាដើរ នាលិកាឈប់ ( ច្រើនថានាលិកាងាប់ ) ៗ

## បង្រៀនមើល

### អាទិត្យទី ១ – អំពីពេលតាមរបៀបខ្មែរ

( សៀវភៅវត្ថុស្វាធ្យាយន៍បរិ. ទំព័រ ១០៨ )

### អាទិត្យទី ២ – អំពីខ្យល់បកមកពីទិសខាជើង

( សៀវភៅខេមរភាសាបរិ. កំព័រ ៦៤ )

## អាទិត្យទី ៣— អំពីភ្លៀង

ទឹកភ្លៀងបង្កើតមកពីពពក ឯពពកកើតឡើងអំពីចំហាយទឹក នៅវេលាដែលត្រូវកំដៅព្រះអាទិត្យ ផ្តុំគ្នាឡើងហើយអណ្តែតទៅលើអាកាស កាលណាពពកនោះរសាត់ទៅប៉ះខ្យល់ត្រជាក់ខាំងកកកទៅជាទឹក ហើយធ្លាក់មកជាទឹកភ្លៀង ទឹកភ្លៀងជ្រាបទៅក្នុងដីសំរាប់ចិញ្ចឹមរុក្ខជាតិទាំងឡាយ ឬផ្តុំគ្នាកើតបានជាដង្ហើមទឹក ។ មួយចំណែកទៀតហូរធ្លាក់ទៅក្នុងថ្លុកត្រពាំងបឹងស្ទឹង , ទន្លេ , សមុទ្រ ។ កាលណាមានភ្លៀងច្រើនមានព្យុះ ផ្គរផ្លេកបន្ទោរហើយនឹងរន្ទះផង ។

ពាក្យពិបាក — ផ្តុំ , អណ្តែត , រសាត់ , រុក្ខជាតិ , ព្យុះ ផ្គរផ្លេកបន្ទោរ ។ ភ្លៀងសរសេរបានពីរយ៉ាង ភ្លៀងឬផ្លៀង ។

## តែងសេចក្តី

### សំរាប់

### ប្រថមភូមិបំពេញវិជ្ជា

ក្នុងខែមិថុនានឹងកក្កដា កម្មវិធីនៅឧត្តមដ្ឋានតម្រូវឲ្យបង្រៀនសាដើមឡើងវិញ ។

ឯនៅមធ្យមដ្ឋាន ត្រូវបង្រៀនអំពីលិខិតក្នុងគ្រួសារ ។ សេចក្តីត្រង់ចំពូកនេះ យើងបានរៀបរៀងកាលពីខែកុម្ភៈរួចហើយ ។

ក្នុងលើកនេះ ដើម្បីជាប្រយោជន៍ដល់សិស្សក្នុងកិច្ចពាក់ទងនឹងរាជការយើងស្រង់ការ នឹងតំណែងសក្តិមន្ត្រីរដ្ឋបាលតាមព្រះរាជក្រមលេខ ១៩ ចុះថ្ងៃ៣ កើតខែផល្គុនឆ្នាំមមីចត្វាស័ក ព.ស.២៤៨៥ ត្រូវនឹងថ្ងៃ៨មិនា ឆ្នាំ១៩៤៣ ។ នឹងមន្ត្រីតុលាការក្រុងខេត្រ ។

## ក- ងារមន្ត្រីរដ្ឋបាលខេត្រ

### ១- ឌីរុកាខេត្រកណ្ដាល

ចៅហ្វាយខេត្រ ៖ ឧកញ៉ារាជមេត្រីសិរីមង្សឹមគ្រាមសេដ្ឋវក

រក្សសិទ្ធិស័ក្តិឧត្តមក្រមពាហុ

ចៅហ្វាយស្រុកភ្នំពេញ ៖ បំរុងរាជា

-ជ- ពញាឮ ៖ ឧទៃយសេនា

-ជ- ខ្សាច់កណ្ដាល ៖ សេនាមេត្រី

-ជ- មុខកំពូល ៖ ផលសាកិមុខ

ចៅហ្វាយស្រុកកៀនស្វាយ ៖ មេត្រីភូធរ

-ជ- ល្វាឯម ៖ ឥស្សូរមេត្រី

-ជ- កណ្ដាលស្ទឹង ៖ វង្សាភូធរ

-ជ- លើកដែក ៖ ឥទ្ធរិជ័យតេជោ

-ជ- ស្អាង ៖ វង្សាមេត្រី

-ជ- កោះធំ ៖ ភក្តីតេជោ

## ២–ឆីរូមខែត្រកំពង់ចាម

ចៅហ្វាយខែត្រ ៖ ឧកញ៉ាមន្ត្រីភក្ដីពិជ័យវង្សមហា បញ្ញកឧត្ដម
ក្រមពាហុ

ចៅហ្វាយស្រុកកំពង់សៀម ៖ ពិជ័យវង្ស

-ដ- ព្រៃឈរ ៖ វល្វិរ័នភក្ដី

-ដ- ជើងព្រៃ ៖ ពេជ្រតេជោ

-ដ- ចំការលើ ៖ ពិភ័ក្ដិអារញ្ញិក

-ដ- កោះសូទិន ៖ ធិបិនមន្ត្រី

-ដ- ត្បូងឃ្មុំ ៖ អរជូន

-ដ- ក្រូចឆ្មារ ៖ ភក្ដីអរជូន

-ដ- មេមត់ ៖ អារញ្ញិកអរជូន

-ដ- ស្ទឹងត្រង់ ៖ រាជាជោ

-ដ- ស្រីសន្ធរ ៖ បវរសង្គ្រាម

-ដ- កងមាស ៖ ពិភ័ក្ដិមន្ត្រី

## ៣ - ឆីរូមខែត្រកំពត

ចៅហ្វាយខែត្រ ៖ ឧកញ៉ាសេនាអនុជិតបុរេន្ទ្រគ្រាម
សិង្ហរគាមឧត្ដមក្រមពាហុ

ចៅហ្វាយស្រុក កំពត ៖ សេនាវិជិត

-ដ- ព្រៃនប់ ៖ វនានុជិត

-ដ- បន្ទាយមាស ៖ យោធាធិបតី

-ដ- កំពង់ត្រាច ៖ រាជាសេដ្ឋី

-ដ- កំពង់សោម ៖ ត្បែសសង្គ្រាម

-ដ- ឈូក ៖ បទុមសេនា

-ដ- កោះកុង ៖ ពិជ័យភឿនឫទ្ធិ

-ដ- ជំនាប់ ៖ ជំនិតសង្គ្រាម

៤ ឌីរួមខេត្តព្រៃវែង

ចៅហ្វាយខេត្ត៖ ឧកញ៉ា នារាធិបតីសិរីសុវត្ថិសក្តិពិភក្តិ ធរនិន្ទសុបរិន្ទពិជ័យ
ឧត្តមក្រមពាហុ ។

ចៅហ្វាយស្រុក ព្រៃវែង ៖ វនាធិបតី

-ដ- កំចាយមារ ៖ ពិភក្តិនារា

-ដ- ពារាំង ៖ ស្រែទ្យសង្គ្រាម

-ដ- ស៊ីធរកណ្តាល ៖ ជវង្គសង្គ្រាម

-ដ- ប៉ាភ្នំ ៖ ធម្មាតេជោ

-ដ- អាំងបញ ៖ វិសេសយោធា

-ដ- កំពង់ត្របែក ៖ វិជិតយោធា

-ដ- ស្រុកកញ្ជៀប ៖ ពិនិត្យសង្គ្រាម

## ៥ - ដីរួមខេត្តកំពង់ឆ្នាំង

ចៅហ្វាយខេត្ត៖ ឧកញ៉ាស្រែនរាធិបតីបុរីរក្សពិភក្តិកម្មការឧត្តមក្រមពាហុ

ចៅហ្វាយស្រុកបរិបូណ៌ ៖ សេនាសង្គ្រាម

-ដ- កំពង់លែង ៖ យសតេជោ

-ដ- កំពង់ត្រឡាច ៖ ស្រែន្យសេនាឫទ្ធី

-ដ- រលាប្អៀរ ៖ ស្រែន្យឫទ្ធី

-ដ- តាំងផ្លាប ៖ សេនាឫទ្ធី

## ៦ - ដីរួមខេត្តតាកែវ

ចៅហ្វាយខេត្ត ៖ ឧកញ៉ាពិស្ណុលោកមហាទ្រូសក្តិពិភក្តិរដ្ឋមហា
បុរន្ទគ្រាមអគ្គសេនាមហាមាត្យឧត្តមក្រមពាហុ

ចៅហ្វាយស្រុក ទ្រាំង ៖ ជំនិតពិស្ណុលោក

-ដ- គិរីវង់ ៖ ពិភក្តិស្នេហាពិស្ណុលោក

-ដ- រមេញ ៖ មន្ត្រីពិស្ណុលោក

-ដ- បាទី ៖ វង្សាអនុជិត

-ដ- សំរោង ៖ ជំនិតវង្សា

-ដ- ព្រៃកប្បាស ៖ ជ័យយោធា

-ដ- ត្រាំកក់ ៖ វិជិតសង្ហាន

### ៧ - និរូបខេត្តស្វាយរៀង

ចៅហ្វាយខេត្ត ៖ ឧកញ៉ាលិបក្រីអធិបតីធរណិន្ទសន្ទោរក្ស
ពិភក្តិរដ្ឋឧត្តមក្រមពាហុ

ចៅហ្វាយស្រុក រំដួល ៖ បំរុងបក្រី
-ដ- ស្វាយទាប ៖ ជយោសង្គ្រាម
-ដ- រមាសហែក ៖ គាមរ័នពិភក្តិ

### ៨ - និរូបខេត្តកំពង់ធំ

ចៅហ្វាយខេត្ត ៖ ឧកញ៉ាតេជោបូភាជ ធរណិន្ទនរិន្ទបរិ
រក្សសមុហាធិបតីអភ័យ តេរីបាភក្រមពាហ,

ចៅហ្វាយស្រុកកំពង់ស្វាយ ៖ សេនាតេជោ
-ដ- សណ្ដាន់ ៖ វិនាភក្តី
-ដ- ព្រំទេព ៖ ទេពភក្តីតេជោ
-ដ- បារាយណ៍ ៖ សែនខាងហ្វា
-ដ- ស្ទោង ៖ មន្ត្រីតេជោ
-ដ- សន្ទុក ៖ សុទិពូមន្ត្រី

### ៩ - និរូបខេត្តសៀមរាប

ចៅហ្វាយខេត្ត ៖ ឧកញ៉ាប្រាសាទកំពីរ្យានទ័ណ្ឌរដ្ឋខេមរ
ពិជ បុរីរក្សនិគមឧត្តមក្រម ពាហុ

ចៅហ្វាយស្រុកសៀមពាង ៖ ប្រសាទសោភ័ណ

-ដ- ពួក ៖ មន្ត្រីពលខន្ធ

-ដ- សូទ្រនិគម ៖ សេនានិគម

-ដ- ជីក្រែង ៖ ស្នេហាមេត្រីតេជា

១០ ធីរូមខែត្រក្រចេះ

ចៅហ្វាយខែត្រ ៖ ឧកញ៉ាមហាជនបទ វង្សគាមហាបុរិន្ទ

គ្រាមពមសេនាធិបតី សិរីអនុរក្សឧត្តម

ក្រម ពា ហុ

ចៅហ្វាយស្រុកក្រចេះ ៖ ជនបទភក្តី

-ដ- សំបូណ៌ ៖ ពិភក្តិបន្ទុគ្រាម

-ដ- ស្នួល ៖ សេនាភក្តី

ចៅហ្វាយស្រុកឆ្លូង ៖ ស្នេហានុរក្ស

១១ - ធីរូមខែត្រកំពង់ស្ពឺ

ចៅហ្វាយខែត្រ ៖ ឧកញ៉ា ឧទយាធិរាជបុរិន្ទ គាមរាម

បុរិន្ទស័ក្តិបត្តតាវនឧត្តមក្រម ពា ហុ

ចៅហ្វាយស្រុកសំរោងទង ៖ អធិរាជវង្សា

-ដ- គងពិសី ៖ វង្សាសមស័ក្តិ

ចៅហ្វាយស្រុក ថ្ពង ៖ រាជាសង្គ្រាម

-ដ- ភ្នំស្រួច ៖ វង្សាឧទ័យ

១២ - ទីរួមខេត្រពោធិសាត់

ចៅហ្វាយខេត្រ ៖ ឧកញ៉ាសួគ៌ាលោក ឥន្ទ្រាបុទ្ធិ

ពិតសង្គ្រាមហានិគមធរណិន្ទស័ក្តិ អគ្គសេនាមហា

មាត្យឧត្តមក្រមពាហុ

ចៅហ្វាយស្រុកបាកាន ៖ សួគ៌ាធិបតី

-ដ- ភ្នំក្រវាញ ៖ អរញ្ញាធិបតី

-ដ- ក្រគរ ៖ ជំនះសង្គ្រាម

១៣ - ទីរួមខេត្រស្ទឹងត្រែង

ចៅហ្វាយខេត្រ ៖ ឧកញ៉ាមន្ត្រីជលធារគាមវរិន្ទមហិន្ទរ

រដ្ឋវិវឌ្ឍសង្គ្រាមរឿងបុទ្ធិឧត្តមក្រមពាហុ ៗ

ចៅហ្វាយស្រុកស្ទឹងត្រែង ៖ រាជាជលធី

-ដ- វិនសៃ ៖ អរញ្ញរឿងបុទ្ធិសិទ្ធិសង្គ្រាម

នៅតំបន់សៀមបូក ៖ ភក្តីសុរិយា

-ដ- សៀមប៉ាង ៖ រក្សាពលខន្ធ

-ដ- ឡូមផាត់ ៖ ឡូមផាត់សេនា

## ខ - ង៉ារមន្ត្រីតុលាការ-ក្រុង-ខេត្ត

### ១ - សាលាសានវិនិច្ឆ័យ

ចាង៍ហ្វាង៍ ៖ ឧកញ៉ាមហាឥស្សរាធិបតី

### ២ - សាលាឧទ្ធរណ៍

ចាង៍ហ្វាង៍ ៖ ឧកញ៉ាមហាវិនិច្ឆ័យ

### ៣ - សាលាឧក្រិដ្ឋ

ចាង៍ហ្វាង៍ ៖ ឧកញ៉ាឥស្សរវិនិច្ឆ័យ

### ៤ - សាលាលុឃុន

ចាង៍ហ្វាង៍ ៖ ពិភក្ដិវិនិច្ឆ័យ

– រង ៖ សេនាវិនិច្ឆ័យ

– លហុ ៖ បំរុងវិនិច្ឆ័យ

### ៥ - សាលាដំបូងកំពុងចាម

ចាង៍ហ្វាង៍ ៖ ឧកញ៉ាពិជ័យវិនិច្ឆ័យ

### ៦ - សាលាដំបូងកំពត

ចាង៍ហ្វាង៍ ៖ ឧកញ៉ាទេសាវិនិច្ឆ័យ

### ៧ - សាលាដំបូងតាកែវ

ចាង៍ហ្វាង៍ ៖ ឧកញ៉ារតនវិនិច្ឆ័យ

៨ - សាលាដំបូងព្រៃវែង

ចាងហ្វាង ៖ ឧកញ៉ា នរវិនិច្ឆ័យ

៩ - សាលាដំបូងស្វាយរៀង

ចាងហ្វាង ៖ ឧកញ៉ា សួរវិនិច្ឆ័យ

១០ - សាលាដំបូងកំពង់ធំ

ចាងហ្វាង ៖ ឧកញ៉ា មហោវិនិច្ឆ័យ

១១ - សាលាដំបូងសៀមរាប

ចាងហ្វាង ៖ ឧកញ៉ា សំរេចវិនិច្ឆ័យ

១២ - សាលាដំបូងពោធិសាត់

ចាងហ្វាង ៖ ឧកញ៉ា សួគ៌ាវិនិច្ឆ័យ

១៣ - សាលាដំបូងកំពង់ឆ្នាំង

ចាងហ្វាង ៖ ឧកញ៉ា ឥទ្ធិវិនិច្ឆ័យ

១៤ - សាលាដំបូងកំពង់ស្ពឺ

ចាងហ្វាង ៖ ឧកញ៉ា សិទ្ធិវិនិច្ឆ័យ

១៥ - សាលាដំបូងក្រចេះ

ចាងហ្វាង ៖ ឧកញ៉ា ចេស្តាវិនិច្ឆ័យ

១៦ - សាលាដំបូងស្ទឹងត្រែង

ចាងហ្វាយ ៖ ឧកញ៉ា នទីវិនិច្ឆ័យ

# ផ្ទាកាំអាគិកផ្ទាន

## តែងសេចក្ដីទី ១

ចូរតែងសេចក្ដីអធិប្បាយអំពីវត្តនៅភូមិអ្នក ។

សេចក្ដីផ្ដើម·— វត្តនៅភូមិអ្នកឈ្មោះវត្តអ្វី ?

វត្តនោះនៅត្រង់ណា ? ទីធ្លាធំឬតូច ? មានអ្វីព័ទ្ធជុំវិញ ? នៅក្នុងទីធ្លានោះអ្នកឃើញមានអ្វីខ្លះ ៗ ព្រះវិហារសង់អំពីអ្វីនៅលើអ្វី ? កុដិលោកសង់អំពីអ្វី ? អ្នកស្រឡាញ់វត្តនោះឬទេ ពីព្រោះអ្វី ?

## សេចក្ដីអធិប្បាយ

នៅភូមិខ្ញុំមានវត្តមួយឈ្មោះវត្តក្ដីដើម ។ វត្តនោះសង់នៅកណ្ដាលភូមិជិតមាត់ស្ទឹង ។ ទីធ្លាធំទូលាយ មានរបងឈើព័ទ្ធជុំវិញ ។ នៅក្នុងទីធ្លាមានដើមស្វាយដើមដូងនិងសួនផ្កា ។ ព្រះវិហារសង់ពីឥដ្ឋនិងស៊ីម៉ងត៍នៅលើដីទួលខ្ពស់ ។ កុដិលោកសង់អំពីឈើប្រក់ក្បឿង ។ ខ្ញុំស្រឡាញ់វត្តនោះណាស់ ពីព្រោះជាទីកន្លែងសំរាប់ចាស់ៗ ទៅសមាទានសីលផងនិងធ្វើបុណ្យទានផ្សេងៗ ផង ។

## តែងសេចក្ដីទី២

ចូរតែងសេចក្ដីអធិប្បាយអំពីបុណ្យណាមួយដែលគេធ្វើនៅវត្តភូមិអ្នក ហើយដែលអ្នកបានទៅឃើញ តើគេរៀបចំដូចម្ដេចខ្លះ មុនធ្វើបុណ្យ កំពង់ធ្វើបុណ្យ ? យោបល់របស់អ្នកយល់ឃើញដូចម្ដេចអំពីធ្វើបុណ្យ ។

## តែងសេចក្ដីទី៣

កាលពីថ្ងៃអាទិត្យមុនអ្នកបានដើរទៅលេង ហើយបានជួបនឹងមនុស្សម្នាក់ ចាស់ជរាពិការជើងទុំកើត ។ អ្នកបានជួយសង្គ្រោះមនុស្សនោះដោយស្មោះត្រង់ ។ ដូច្នេះចូរអ្នកអធិប្បាយអំពីសេចក្ដីដែលអ្នកបានធ្វើដូចម្ដេចៗ ។ លុះបានជួយស្រោចស្រង់រួចហើយតើអ្នកសប្បាយក្នុងចិត្តឬទេ ពីព្រោះអ្វី ?

## ថ្នាក់វិជ្ជណាដ្ឋាន

## តែងសេចក្ដីទី ១

ចូរតែងសេចក្ដីអធិប្បាយអំពីក្មេងស្អាតម្នាក់ដែលនៅរៀនថ្នាក់ជាមួយនឹងអ្នក

### របៀបអធិប្បាយ

១- សេចក្ដីផ្ដើម ។ ២· អំពីកេពារទនឹងកិរិយា ។ ៣. ពេលព្រឹកក្រោកពីដេកពេលចេញទៅរៀន ។ នៅកំពង់រៀន ។ យោបល់យល់ឃើញរបស់អ្នក ។

### គំរូតែងសេចក្ដី

នៅក្នុងថ្នាក់រៀនខ្ញុំ មានក្មេងម្នាក់ស្អាតណាស់ តែងតែរក្សាភាពពេលព្រឹកកាលណាវាក្រោកពីដេកវាលុបមុខដុសធ្មេញលាងដៃ ជើងជូតនឹងកន្សែងឆ្លុះកញ្ចក់សិតសក់យ៉ាងស្អាត រួចស្លៀកពាក់ខោអាវ រៀបចំសៀវភៅកណ្ដៀតដើរចេញទៅសាលារៀន ។ នៅកំពង់ពេលរៀនក្មេងនោះ

អង្គុយស្ងៀមមិនងៀកឆ្វេងស្ដាំប្រុងស្មារតីចាំស្ដាប់គ្រូពន្យល់ ។ យោបល់ខ្ញុំយល់ឃើញថាកុមារទាំងឡាយត្រូវយកតំរាប់កុមារខាងលើនេះ ។

## តែងសេចក្ដីទី ២

ចូរតែងសេចក្ដីអធិប្បាយអំពីភូមិអ្នក តាមពាក្យចោទខាងក្រោមនេះ ។

អ្នកនៅភូមិណា? ភូមិនោះតូចឬធំ ។ នៅខាងណាសាលារៀនអ្នក? ខាងជើងខាងត្បូងខាងកើតខាងលិចទល់នឹងភូមិណាខ្លះ ។ នៅក្នុងភូមិអ្នកមានផ្ទះច្រើនឬតិច ។ មានដើមឈើអ្វីខ្លះ ។ នៅរដូវវស្សាភូមិអ្នកលិចទឹកឬទេ? នៅរដូវប្រាំងដីក្នុងភូមិអ្នកយ៉ាងដូចម្ដេច ? អ្នកស្រឡាញ់ភូមិអ្នកឬទេ ។ ពីព្រោះអ្វី ។

## តែងសេចក្ដីទី ៣

ចូរតែងសេចក្ដីអធិប្បាយអំពីផ្ទះអ្នកតាមពាក្យចោទខាងក្រោមនេះ ។

ផ្ទះអ្នកសង់នៅភូមិណា ? ផ្ទះនោះសង់ខ្ពស់ឬទាបពីដី ។ បែរមុខទៅទិសខាងណា ។ សសរធ្វើពីអ្វី ដំបូលប្រក់អ្វីជញ្ជាំងធ្វើពីអ្វី ។ ក្រាលរនាបឬស្សីឬក្រាលក្ដារ ។ ផ្ទះនោះមានបន្ទប់ប៉ុន្មាន? បន្ទប់អ្វីខ្លះ ។ អ្នកស្រឡាញ់ផ្ទះអ្នកឬទេពីព្រោះអ្វី

## អាធិកាដ្ឋាន

### នព្វន្ត

លេខចែកនឹង ១០ - ១០០ - ១០០០

ដើម្បីនឹងចែកចំនួនអ្វីមួយនឹង ១០- ១០០- ១០០០ នោះគេគ្រាន់តែខណ្ឌដោយកណ្ដក់ខាងស្ដាំចំនួននោះ មួយខ្ទង់ចំនួនណាដែល ចែកនឹង ១០ពីរខ្ទង់ចំនួនណាដែលចែកនឹង ១០០ បីខ្ទង់ចំនួនណាដែលចែកនឹង ១០០០

ឧបមា ១២៥ : ១០ " ១២,៥

១២៥ : ១០០ " ១,២៥

១១២៥ : ១០០០ " ១,១២៥

បើខ្វះលេខនៅខ្ទង់ណាគេដាក់សូន្យបង្គ្រប់ខ្ទង់នោះ

ឧបមា: ៧ : ១០ " ០,៧

២៥ : ១០០ " ០,២៥

១២៥ : ១០០០ " ០,១២៥

វិធីហាត់មាត់ទទេ ចែកចំនួនទាំងអស់នេះ

នឹង១០០០-២៣៥៣រ ។ ៩០២ ម ។ ៧៣៥១៩ ល ។

ទីង១០០ - ២៤០រ ៗ ៤៩ម ៗ ២១៧៨ ល ៗ

ទីង ១០ - ៧រ ៗ ១០៩ ម ៗ ៤៣៥០ល ៗ

សៀវភៅមើល១០០ថ្ងៃ ១២៣៥រ ៗ តើសៀវភៅមើលមួយថ្ងៃប៉ុន្មាន ៗ ស្រា ១ ធុង១០០០លីត្រថ្លៃ១៩៥៣៩រុ ៗ តើមួយលីត្រថ្លៃប៉ុន្មាន ៗ

## វិធីហាត់សរសេរ បំណោទ

១ លីត្រមានប៉ុន្មានដេស៊ីលីត្រ ៗ

មានប៉ុន្មានមីលីលីត្រ ទើបបាន ១ លីត្រ ៗ

មានប៉ុន្មានសង់ទីលីត្រក្នុង២លីត្រ ៗ ៥ដេកាលីត្រ ៗ

បំណោទៈ គេដាក់ទឹកនៅក្នុងថាំងធំមួយ ៗ លើកដំបូង២ហ.លកន្ទះ មួយលើកបន្ទាប់ ៤ ដា.ល.កន្ទះហើយលើកក្រោយបំផុត ២៤ល គេសួរថា ចុះគេចាក់ទឹកទៅក្នុងថាំងនោះទាំងអស់ប៉ុន្មាន ៗ

ឈ្មួញម្នាក់ទិញស្រា៣ធុងបំណុះ២២៥លីត្រក្នុង ១ ធុង តើស្រានោះថ្លៃប៉ុន្មានទាំងអស់ បើក្នុង១ហិកតូលិត្រ ថ្លៃ ១៤០រុ ៗ

លូ ១ ដេកាលិត្រថ្លៃ ១៦រុ៩០ តើលូ១២ការុង ថ្លៃប៉ុន្មាន បើក្នុង ១ការុងមានបំណុះ ២ហ.លុកន្ទះ

អ្នកលក់សត្វទិញស៊ុតមានចំនួន១០០០ ថ្លៃ៤២០រុ តើស៊ុតមាន់ ១ឡូ ថ្លៃប៉ុន្មាន ៗ

អ្នកជំនួញម្នាក់ទិញស្រាទំពាំងបាយជូរ ៤ ធុងចំណុះក្នុង១ធុង ២០០ លីត្រថ្លៃជាប្រាក់១៤.៥៣០៛ ។ តើក្នុង ១ លីត្រទិញថ្លៃប៉ុន្មាន ។

## លេខចែកបែងភាគគត់

(លេខតាំងដែលគ្មានចំនួនបែងភាគគត់ )

ឧបមា: ៦២៣:៤៥ :

| | | |
|---|---|---|
| ៦២៣០ | ៤៥ | គេត្រូវធ្វើដើមហារនោះ ( ៤៥ ) |
| ១៧៣ | ១៣៨ | ឲ្យទៅជាចំនួនធំ ( ៤៥ ) ដូច្នេះ |
| ៣៨០ | | គេត្រូវលុបក្បៀសក្នុង |
| ២០ | | ដើមហារនោះហើយគេត្រូវថែម |

សូន្យនៅលេខតាំង ( ៦២៣ ឲ្យ

ទៅជា ៦២៣០ ) តាមចំនួនលេខ

ក្នុងចំណែកបែងភាគជាដើមហារនោះ ។

**វិធីហាត់សរសេរ** ចូរធ្វើលេខចែកខាងក្រោមនេះ

៦៤ម:៥៤ : ។ ៨៧០៤ : ៥៣

៤៣៧:៣២ : ។ ២៥៩៣ : ៤៣ :

## បំណោទ

គេទិញទា១ថ្លៃ១២រុ២៥ តើគេទិញបានទាប៉ុន្មាន បើគេមានប្រាក់៩៨រុ ។

សំពត់ ១ ផាប់មាន ៤៨ម,៣៥លក់ថ្លៃទាំងអស់១៨៣៦ តើមួយម៉ែត្រ លក់ថ្លៃប៉ុន្មាន ។

សូមបង្រៀនសិស្សឲ្យធ្វើ ចំណោទក្នុងលេខទាំងបួនបែបឡើងវិញ ។

## រង្វាស់រង្វាល់

### សាបង្រៀនអំពីរង្វាស់ប្រវែងឡើងវិញ

វិធីហាត់មាត់ទទេ - ខ្នាតដើមនៃវិធីវាស់ប្រវែងនោះគឺអ្វី ? ។

ម៉ែត្រមានប៉ុន្មានយ៉ាង ។ ម៉ែត្រគេធ្វើអំពីអ្វីខ្លះ ។ រង្វាស់តូចជាងម៉ែត្រនោះ គឺអ្វីខ្លះ ។ ខ្នាតធំជាងម៉ែត្រ អ្វីខ្លះ ។

វិធីហាត់សរសេរ - ឲ្យសរសេរជាម៉ែត្រចំនួនខាងក្រោមនេះ ។

៨ ហម ។ ២៣ ដាម ។ ២៥ សម ។ ៧ ហម ។ ៨-០០០ ម-ម ។

៨៥៣ សម ។ ៤ ដ-ម ។

ចំណោទ—អ្នកវេញខ្សែម្នាក់ វេញខ្សែនៅថ្ងៃចន្ទ បាន៣៥ម, ថ្ងៃអង្គារបាន ៤ ដា.ម លើសថ្ងៃចន្ទ ហើយថ្ងៃពុធបាន៨ម៉ែត្រ លើសថ្ងៃអង្គារទៀត តើក្នុង៣ថ្ងៃនោះ គេវេញខ្សែបានប៉ុន្មានម៉ែត្រ ។

ពីភ្នំពេញទៅកំពង់ឆ្នាំងមានចម្ងាយ ៨៩ គ.ម. ពីកំពង់ឆ្នាំងទៅពោធិសាត់មានចម្ងាយ១០០ គ.ម តើពីភ្នំពេញទៅពោធិសាត់មាន

ចម្ងាយប៉ុន្មាន ។

# សាបង្រៀនពីរង្វាល់ចំណុះ

វិធីហាត់មាត់ទទេ—មួយហិកតូលីត្រមានប៉ុន្មានដេកាលីត្រ ?

មានប៉ុន្មានលីត្រ ក្នុង ៥ ដា.លី ? ៧ ហ.លី ?

កន្លះដេកាលីត្រមានប៉ុន្មានលីត្រ ?

កន្លះហិកតូលីត្រមានប៉ុន្មានដេកាលីត្រ ?

ចង្កៀង១ស៊ីប្រេងកាតក្នុង១ខែ៦លីត្រ តើក្នុង១ឆ្នាំវាស៊ីអស់ប៉ុន្មានលីត្រ ?

---

## កុមារដ្ឋាន

**នព្វន្ត**

តាមកំណត់ចែកវិជ្ជាក្នុងខែនេះជាខែចុងឆ្នាំសិក្សាត្រូវសាបង្រៀនមេរៀនផ្សេងៗ ដែលបានបង្រៀនតាំងពីដើមឆ្នាំមក ឲ្យសិស្សហាត់ធ្វើលេខធ្វើចំណោទផ្សេងៗ តាមដំរិះរបស់សិស្ស ។

សូមមើលតាមរបៀបរៀបចំជាគំរូក្នុងទស្សនាវដ្តីខែមុន ហើយសូមតែងការហាត់ឲ្យសព្វគ្រប់តាមចំណេះរបស់សិស្ស ។

# រង្វាស់រង្វាល់

សូមសាបង្រៀនមេរៀនផ្សេង ៗ ដែលសិស្សបានរៀនតាំងពីដើមឆ្នាំមក ៗ ឲ្យសិស្សហាត់ធ្វើលេខនឹងធ្វើចំណោទឲ្យបានច្រើនផង ៗ

---

បរិវច្ឆណដ្ឋាន

## ផលូន

មេរៀន ទី ១ .– សាបញ្ជាក់អំពីលេខបូកចំនួនគុំនឹងចំនួនបែងភាគ ៗ

របៀបបង្រៀន .- ចោទជាបំណោទ ៖

១ – ម្តាយខ្ញុំគាត់ទិញសំពត់ ៥ ម៉ែត្រអស់ប្រាក់ ៤៥ រៀល ទិញត្រីសាច់នឹងបន្លែ អស់ ២៧ រៀល ៗ តើគាត់ចាយអស់ប្រាក់ប៉ុន្មានទាំងអស់

២ – ឪពុកខ្ញុំគាត់ទិញសៀវភៅមើល ១ ថ្ងៃ ១៥៍៥០ ទិញសៀវភៅសរសេរ ១០ ថ្ងៃ ២៣៍៧០ ៗ តើគាត់ចាយអស់ប្រាក់ប៉ុន្មានទាំងអស់

របៀបពន្យល់ .– ដាក់ចំណោទខាងលើនេះមួយម្តងឲ្យសិស្សធ្វើទាំងអស់គ្នានៅលើក្តារខៀនដោយមាត់ទទេ ហើយពន្យល់សិស្សដោយចោទសួរថា ៖

– កូនចំណោទនេះគេសួរតើអ្វី ។ ត្រូវធ្វើដូចម្តេច ។

– ចូរធ្វើលេខបូកនោះនៅលើក្តារខៀនទៅមើល ។

បើពិនិត្យទៅឃើញថាសិស្សនៅពុំទាន់យល់ច្បាស់ត្រង់កន្លែងណា ត្រូវពន្យល់បំពេញកន្លែងនោះឲ្យសិស្សយល់ច្បាស់ឡើង ។

## ការហាត់សរសេរនៅក្នុងសៀវភៅ. បំណោទ

១ – ស្រីម្នាក់ទៅផ្សារទិញអង្ករ ១តៅអស់ប្រាក់ ៤៧ រៀល ទិញសំពត់ ៣ ម៉ែត្រអស់ ៥០៛ ទិញត្រីសាច់នឹងបន្លែអស់ ២៤ រៀល ។ តើស្រីនោះចាយអស់ប្រាក់ប៉ុន្មានទាំងអស់ ។

២ – អ្នកចំការម្នាក់ទៅផ្សារលក់ផ្លែឈើបានប្រាក់ ២៥៛ ៥០ លក់បន្លែបាន ១៧៛៧០ ។ តើអ្នកចំការនោះលក់បានប្រាក់ទាំងអស់ប៉ុន្មាន ។

## មេរៀនទី ២ សាបច្រៀនអំពីលេខសងចំនួនដុំនឹងចំនួនបែងភាគ ។

សូមមើលតាមរបៀបខាងលើនេះ ហើយតែងការហាត់ឲ្យសព្វគ្រប់ផង ។

## ការហាត់សរសេរនៅក្នុងសៀវភៅ បំណោទ

១ – ម្តាយខ្ញុំគាត់លក់មាន់ពីរបានប្រាក់ ៣៧ រៀល លក់បន្លែនឹង

ផ្លែឈើបានប្រាក់២៩ រៀល ហើយគាត់ចាយអស់១៥ រៀល ។ តើគាត់នៅសល់ប្រាក់ប៉ុន្មានរៀលទៀត ។

២– ឪពុកខ្ញុំគាត់មានប្រាក់១១៧៛៥០ គាត់ចាយទិញស្រោមជើង១ សំពត់អស់ ៣៤៛៤០ ទិញខ្សែក្រវាត់ស្បែក១អស់ ២៣៛៧០ ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានទៀត ។

មេរៀនទី ៣.– សាបញ្ជាក់អំពីលេខគុណចំនួនដុំនិងចំនួនបែងភាគ ។

ការហាត់សរសេរនៅក្នុងសៀវភៅ.. ចំណោទ

១– ម្តាយខ្ញុំគាត់ទិញសំពត់ ស ៥ ម៉ែត្រថ្លៃ១៧ រៀលក្នុង១ម៉ែត្រ ហើយនឹងអំបោះដេរអស់១៣ រៀល តើគាត់ចាយទាំងអស់ៗប្រាក់ប៉ុន្មាន

២– ឪពុកខ្ញុំគាត់មានប្រាក់៩៣៛៥០ គាត់ទិញសាច់គោ៧ គីឡូក្រាមថ្លៃ១២៛៣៧ក្នុង១គីឡូក្រាម ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានទៀត ។

មេរៀនទី ៤.– សាបញ្ជាក់អំពីលេខចែកចំនួនដុំនិងចំនួនបែង-ភាគ (លេខហារមានតែមួយតួ)

ការហាត់សរសេរនៅក្នុងសៀវភៅ. ចំណោទ

១– អ្នកជំនួញម្នាក់លក់អង្ករ៦ ហាប ថ្លៃ ១៤០ រៀល ក្នុង១ហាប

ហើយយកប្រាក់នោះទៅទិញបានកូនគោ ៤ ។ តើកូនគោមួយត្រូវជាថ្លៃប៉ុន្មាន ។

២– ម្តាយខ្ញុំគាត់លក់មេមាន់៩ ថ្លៃ ១៥៛៥០ កាក់មេមាន់មួយ ហើយគាត់យកប្រាក់នោះទៅទិញបានកូនជ្រូក ៣ ។ តើកូនជ្រូកមួយត្រូវជាថ្លៃប៉ុន្មាន ។

## រង្វាស់រង្វាល់

មេរៀនទី.១– សាបញ្ញាក់អំពីរង្វាស់ (ម៉ែត្រ) រង្វាស់ដែលធំជាងម៉ែត្រ-និងរង្វាស់ដែលមានជាប្រធាន ។

មេរៀនទី២– សាបញ្ញាក់អំពីរង្វាស់ (លិត្រ) រង្វាស់ដែលធំនិងតូចជាងលិត្រ-រង្វាស់ដែលមានជាប្រធាន ។

មេរៀនទី ៣– សាបញ្ញាក់អំពីកូនទម្ងន់ (ក្រាម) កូនទម្ងន់ដែលតូចនិងធំជាងក្រាម- កូនទម្ងន់ដែលមានជាប្រធាន ។

មេរៀនទី៤– សាបញ្ញាក់អំពីប្រាក់ដែលចាយនៅប្រទេសឥណ្ឌូចិន ។

ការបំណាំ- សូមបង្ហឹកសិស្សឲ្យចេះវាស់.វាល់. ថ្លឹង ដូរ ប្រាក់ ថែមថយប្រាក់បានស្ទាត់ផង ហើយតែងការហាត់ឲ្យបានសព្វគ្រប់ផង ។

## អាទិកដ្ឋាន

## វិត្តស្វាយផ្សាយន៍

សេចក្តីណែនាំ      ក្នុងខែនេះត្រូវបង្រៀនសាដើមគឺត្រូវជ្រើសរើសធ្វើពាក្យសួរដើម្បីរំលឹកសិស្ស អំពីមេរៀនទាំងឡាយដែលបានបង្រៀនមកក្នុងឆ្នាំសិក្សា ហើយចំពោះមេរៀនណាដែលសំខាន់ត្រូវលើកយកមកបង្រៀនឲ្យសិស្សបានជ្រួតជ្រាបដោយហ្មត់ចត់ ។

មេរៀនទាំងឡាយ ដែលបានតែងដូចតទៅគឺមានក្នុងកម្មវិធីប្រចាំឆ្នាំ តែដែលមិនទាន់បានចុះក្នុងទស្សនាវដ្តីនេះនៅឡើយ ។

### អាទិត្យទី១– ឧស្សាហកម្ម

ដែលហៅថាឧស្សាកម្ម      គឺការធ្វើឲ្យវត្ថុដើមផ្លាស់ប្តូរភាពក្លាយទៅជាប្រដាប់ប្រើប្រាស់បាន ។ គឺដោយសារឧស្សាហកម្មនេះហើយបានជាស្បែកសត្វទាំងឡាយផ្លាស់ប្រែទៅជាស្បែកសម្លាប់ល្អបាន ។ ឯស្បែកសម្លាប់នេះគេយកទៅធ្វើជាវត្ថុប្រើប្រាស់គ្រប់យ៉ាង ។

នៅក្នុងរោងអារឈើ      គេបំបែកឈើឲ្យទៅជាក្តារ ,ហើយក្តារនេះ; ពួកជាងឈើ, ជាងគ្រឿងផ្ទះ , ជាង តុ-ទូ ធ្វើគ្រឿងតុបតាំងហើយនិងវត្ថុធ្វើអំពីឈើច្រើនយ៉ាងទៀត ។ នៅក្នុងរោងរំលាយលោហធាតុគេយករ៉ែទៅរំលាយជាដែក , ជាស្ពាន់និងដែកថែប ។ នៅក្នុងរោង

តម្បាញ, គេយកពេមជាម, កប្បាស, សូត្រ រវៃទៅជាសរសៃធ្មារ, សរសៃ; នេះសំពប់តម្បាញជាសាក្លាតជាក្រណាត់គ្រប់យ៉ាង ។ ក្នុងពេលធ្វើស្ករ គេយកអំពៅនឹងឆាយថាវ (Betterave) ទៅធ្វើស្ករបន្ទះលឿនៗឬមួយគេយកទៅរំងាស់ឲ្យស្ករនោះសស្គុសក៏បាន ដើម្បីប្រើការក្នុងចំណីអាហារ ។

## អាទិត្យទី ២– លោហធាតុ

លោហធាតុច្រើននៅក្នុងព្រះធរណីមានភាពជារ៉ែ ៗ ដែលហៅថារ៉ែ គឺលោហធាតុផ្សេងៗលាយនឹងសិលាជាតិ ។ មាសមិនដូចលោហធាតុឯទៀតទេ នៅក្នុងព្រះធរណី គេបានប្រទះ មាសសុទ្ធតែឯងឥតមានលាយនឹងសិលាឯទៀតទេ ។ រ៉ែទាំងឡាយនៅក្នុងដីមានភាពជាស្រទាប់ខ្សែរ៉ែង ជាគំនរធំឬជាដុំធំត្រួតៗលើគ្នា ។ លោហធាតុមានលក្ខណៈដូចតទៅ ៖

លោហធាតុមានពណ៌ផ្លេកពីសេសនាំឲ្យគេងាយសំគាល់ ស្វិត ហើយជាប់ផង ។ គេអាចវាយឲ្យសំប៉ែតជាផ្ទាំងបាន ហូតជាលួសក៏បាន គេយកទៅរំលាយបានដោយកំដៅភ្លើង ។ ក្នុងចំណោមលោហធាតុទាំងអស់មានតែបារតមួយទេ ដែលជាលោហធាតុមានភាពរាវក្នុងកំដៅធាតុអាកាសធម្មតា ។

លោហធាតុទាំងឡាយសឹងជាគ្រឿងឯកក្នុងការដឹកនាំធាតុក្តៅនឹងអគ្គិសនី ។

## អាទិត្យទី៣ — ឧស្សាហកម្មខាងត្រី

ត្រីជាអាហារមួយយ៉ាងវិសេស ដែលគេបរិភោគស្រស់ក៏បានឬធ្វើទុក សម្រាប់បរិភោគឲ្យបានយូរក៏បាន ។

គេយកត្រីមកធ្វើជាទឹកត្រីឬជាប្រហុក មាំ ផ្អក ។ ប្រទេសកម្ពុជា ជាប្រទេសបរិបូណ៌ខាងត្រីណាស់ៈ គេដឹកចេញទៅលក់នៅបរទេសជាពល់ឆ្នាំ ( ប្រទេសចិន ជប៉ុន ហ្វាក៉ ( Java )

ដើម្បីទុកត្រីឲ្យបានយូរ គេយកទៅហាលថ្ងៃឲ្យស្ងួត ឆ្អើរនៅលើចង្អើរឬ ប្រឡាក់ទុកក្នុងពាង ។

## អាទិត្យទី៤ — ឧស្សាហកម្មខ្លះកើតឡើងអំពីសត្វ

សត្វដែលគេសម្លាប់រួចហើយ គេព្រលាត់យកស្បែកវាហើយគេ លើយយកសាច់ចេញ ។ ស្បែកនេះគេទុកតាំងពេមហើយយកទៅធ្វើជា សំលៀកបំពាក់សម្រាប់រដូវរងា ។

មានស្បែកខ្លះទៀត គេយកទៅសម្លាប់ ដោយប្រើសំបកឈើដូច ជាសំបកដើមគោងកាង ស្លាប់ កណ្ដោល ។ ល ។ ស្បែកនេះមាន ពណ៌ច្រើនយ៉ាង រលោងផ្លុះ ហើយមិនអាចទីងផុយ រលួយឬទឹកចូល បានដោយងាយទេ គេយកទៅធ្វើវត្ថុបានច្រើនយ៉ាងដូចជា៖ ស្បែកជើង ហឹប កំផ្លោត ។ ល ។

គេយកស្រកាអណ្ដើកសមុទ្រទៅធ្វើប្រដាប់ប្រើច្រើនមុខឯស្នូកវាគេធ្វើជាគ្រឿងលំអ ។

ស្នែងក្របី ស្នែងគោ និងភ្លុកដំរីគេយកទៅធ្វើប្រដាប់ប្រើប្រាស់គ្រប់យ៉ាង ។

---

## អាធិកដ្ឋាន

### នព្វន្ត

ទី ១- សាបស្រៀនអំពីលេខបូកតាំងពីយ៉ាងឡើងវិញ ។

១,- វិធីហាត់គិតឥតធ្វើលេខ- លេខបូកជាអ្វី? (ជាវិធីមួយសំរាប់ប្រមូលចំនួនអ្វីដែលដូចគ្នាមកធ្វើជាចំនួនមួយ) ។ ដើម្បីនឹងសរសេរហើយនឹងបូកលេខនោះ គេត្រូវសំគាល់ដូចម្ដេច? គេត្រូវសំគាល់ខ្លួនគឺ ចំនួនកាយក្រោមចំនួនកាយ ចំនួនដប់ក្រោមចំនួនដប់ ។ ល ។-

២-វិធីហាត់សរសេរ-ចូរធ្វើលេខបូកដូចមានដាក់នៅខាងក្រោមនេះ

៦៦១៣៛ + ២៣៛ + ៥៣៦៛ = ... ២២៧ម + ៧៩៤ម៥: ......

២៤៦៛៧ + ៥៨៛៥៦ + ៩៦៣៛៥: ...២៩៩ម៧២ + ៩៦២ម:......

៣- ចំណោទ:- ទូកប៉ុកចាយមួយផ្ទុកឥដ្ឋបីថ្ងៃ ក្នុងថ្ងៃទី១ ផ្ទុកបាន

៦៨៥ ដុំ ថ្ងៃទី ២បាន ៤៦៩ដុំ ថ្ងៃទី៣បានស្មើទីទៃថ្ងៃទី១នឹងថ្ងៃទី២រួមគ្នា តើក្នុង៣ថ្ងៃទូកនោះផ្ទុកបានឥដ្ឋប៉ុន្មានដុំ ? ។

៤– អ្នកស្រែបំការម្នាក់បានទិញស្រូវ ២៧ហល ថ្លៃ១៩៨៨៛ ៧៥ រួច ៣៧ហល៥០ ថ្លៃ ៤៧៥៛ ៥០ តើអ្នកស្រែនោះទិញទាំងអស់បានប៉ុន្មានហិកតូលីត្រ ? ហើយត្រូវលក់ស្រូវនោះទៅវិញថ្លៃប៉ុន្មានឲ្យបានចំណេញ ១២៩០៛៧៥.។

ទី២– សាបរៀនអំពីលេខសងឡើងវិញ ។

១– វិធីហាត់គិតឥតធ្វើលេខ·– លេខសងជាអ្វី ? (ជាវិធីមួយសំរាប់ដកឬកាត់ចំនួនតូចមួយពីចំនួនធំមួយ)។ គេធ្វើលេខសងដូចម្តេច? (គេសរសេរចំនួនតូចដាក់ក្រោមចំនួនធំឲ្យត្រង់ជួរ គឺខ្ទង់រាយក្រោមខ្ទង់រាយ ខ្ទង់ដប់ក្រោមខ្ទង់ដប់ ។ល។

២– វិធីហាត់សរសេរ·– ចូរធ្វើលេខសងខាងក្រោមនេះបានធ្វើបញ្ជាក់ឲ្យដឹងខុសត្រូវផង ។

២៨៧៧ម-៤៣៩ម-...។ ១៥៣២ម-៧៥៣ម២៥-...។ ៩៩២៛៨-៥៣៦-....។ ៧៩២៣៛៦៥-២៨៤៛៧៨-....។

៣– ចំណោទ.– ជាងឈើម្នាក់មានប្រាក់២២៥៣៨៛៥០ ហើយគេទិញឈើមួយកន្ទង់អស់៧៦៣៤៛២៥ មួយកន្ទង់ទៀតអស់៨២៨៦៛៦០ តើជាងនោះសល់ប្រាក់ប៉ុន្មានទៀត ។

៤– ជាងឆ្នៅម្នាក់ចេញថ្លៃឲ្យកូនជាង៣នាក់ចំនួនប្រាក់៧០០៛ ។ កូនជាងទីមួយបាន២៩៧៛៧៥ ជាងទីពីរបានតិចជាងទីមួយ ៣៩៛៥០ ហើយជាងទី៣ត្រូវបានប្រាក់ដែលនៅសល់ តើម្នាក់ត្រូវបានប៉ុន្មាន? ។

ទី៣– សាបច្រៀនអំពីលេខគុណចំនួនដុំនឹងចំនួនទសភាគ លេខគុណនឹង១០ៗ១០០ៗ១០០០ៗ ហើយនឹងរបៀបធ្វើបញ្ជាក់ឲ្យឃើញខុសត្រូវនោះឡើងវិញផង ។

វិធីហាត់គិតឥតធ្វើលេខ–លេខគុណជាអ្វី? (ជាវិធីមួយសំរាប់បង្កើនចំនួនមួយឲ្យចំរើនធំឡើងមានកំណត់) លេខតំណាំងគឺអ្វី? មេគុណគឺអ្វី?ៗ

មួកមួយថ្លៃ៥៛ បើមួក ៥ ៗ ១ ៗ ១០០ ៗ ១០០០ ៗ ថ្លៃប៉ុន្មាន ៗ តើធ្វើដូចម្ដេចដើម្បីនឹងគុណចំនួនគត់នឹង ១០ ៗ ១០០ ៗ ១០០០ ៗ បើលេខតំណាំងជាចំនួនមានបែងភាគរាយគេធ្វើដូចម្ដេច ។ ល ។

២– ចំណោទ-ចិនម្នាក់ទិញមួក ៥២ ហើយលក់ទៅវិញថ្លៃ១៨៛មួយ រួចចិននោះគិតឃើញចាំងអស់ ៦៣០៛ តើថ្លៃដើមមួកនោះចាំងអស់ប៉ុន្មានៗ

៣– ជាងឈើម្នាក់រកបានក្នុងមួយថ្ងៃ ១៦៛ ៥០ វាធ្វើការរាល់ថ្ងៃ ១ឆ្នាំ លើកតែ៥២ថ្ងៃអាទិត្យ ហើយនឹងថ្ងៃបុណ្យ ៦ថ្ងៃចេញ ។ ថ្លៃឈ្នួលផ្ទះ ៧២០៛ ហើយសន្សំទុកបាន ៦០០៛ តើជាងនោះនៅសល់ប្រាក់ប៉ុន្មាននឹងចាយរាយក្នុងគ្រួសារ! ។

ទី ៤ សាបង្រៀនអំពីលេខបែកដែលបានបង្រៀនក្នុងឆ្នាំនេះឡើងវិញ ។

១. វិធីហាត់មាត់ទទេ — សូមមើលវិធីនេះក្នុងកិច្ចសិក្សាបឋមវិជ្ជា តាំងពីខែសេបតមប្រ៍រហូតមកដល់ខែម៉ែនេះ ។

២ — បំណោទ- ឈ្មួញម្នាក់ទិញសំពត់ហូល ៨ ហើយលក់ទៅវិញទាំងអស់បានប្រាក់ ៦៤០រៀល គេគិតទៅឃើញបានចំណេញ ១៦០រៀល តើថ្លៃដើមសំពត់នោះមួយប៉ុន្មាន ? ។

## រង្វាស់រង្វាល់

ទី — ១- សាបង្រៀនអំពីរង្វាស់ប្រវែងឡើងវិញ ។

១— វិធីហាត់គិតឥតធ្វើលេខ- ខ្នាតដើមនៃវិធីវាស់ប្រវែងនោះគឺអ្វី ? ម៉ែត្រគេធ្វើអំពីអ្វី? មានបែបយ៉ាងណាខ្លះ? រង្វាស់តូចជាងម៉ែត្រនោះគឺអ្វីខ្លះ? ខ្នាតធំជាងម៉ែតនោះគឺអ្វីខ្លះ?

២— វិធីហាត់សរសេរៈ ឲ្យសរសេរៈ ជាម៉ែត្រចំនួនខាងក្រោយនេះ

១៧ម ។ ៨ហ.ម ។ ៣២ដ.ក ។ ២៥ស.ម ។ ៧ហ.ម ។ ៨០០០ម.ម ៨៥៣ស.ម ។ ៤ដ.ម២៥ស.ម ។

៣ – បំណោទ- អ្នកវេញខ្សែម្នាក់វេញខ្សែ នៅថ្ងៃចន្ទបាន ៣៥ម៉ែត្រ

ថ្ងៃអង្គារបាន៨ម៉ែត្រ លើសថ្ងៃច័ន្ទ ហើយថ្ងៃពុធបាន៩ម៉ែត្រលើសថ្ងៃអង្គារទៀត ។ តើក្នុង៣ថ្ងៃនោះគេវេញខ្សែបានប៉ុន្មានម៉ែត្រ?

ឈ្មួញម្នាក់ជំពាក់ទំនិញគេ៩៦៦ៀ៥០ វាសងជាប្រាក់១២៥ៀ៥០ ហើយនៅសល់ប៉ុន្មានទៀតជាសំពត់គិតថ្លៃ១៤ៀក្នុង១ម៉ែត្រ។ តើឈ្មួញនោះត្រូវសងសំពត់ទៅគេប៉ុន្មានម៉ែត្រ? ។

ទី២– សាបង្រៀនអំពីរង្វាល់ចំណុះ

វិធីហាត់ឥតធ្វើលេខ - ចោទសួរពិចារណាអំពីវាល់ នឹងផ្លាស់រង្វាល់ធំទៅតូចរួចតូចមកធំវិញ ។

២– ចំណោទ - គេចាក់ទឹកទៅក្នុងថាំងធំមួយៗ លើកដំបូង២ហ.លកន្លះ មួយលើកបន្ទាប់៤ដ.ក កន្លះ ហើយលើកក្រោយបំផុត២៤លីត្រ គេសួរថាចុះគេចាក់ទឹកទៅក្នុងថាំងនោះទាំងអស់ប៉ុន្មានលីត្រ? ។

ទី៣ទី៤ - ១- សាបង្រៀនអំពីរង្វាល់ចំណុះដែលមានរូបជាក់ស្តែងគឺរង្វាល់ដែលមានធ្វើទុកគាន់វាល់ផ្ទាល់នឹងដៃបាន ។

២ – សាបង្រៀនអំពីរូបិយវត្ថុដែលបានបង្រៀនរួចមកហើយ ។

ចំណោទ – ១ - ចិនម្នាក់ទិញស្រា១៥ដុទិនថ្លៃ១ដុទិន៦២ៀ៥០ ហើយចិននោះលក់រាយទៅវិញ១០ៀ៣០ក្នុង១លីត្រ តើចិននោះចំណេញបានប៉ុន្មាន បើក្នុង១ដុទិនមានចំណុះ២ដ.ក.លកន្លះ? ។

២— មានបងប្អូន៣នាក់ទៅស៊ីឈ្នួលឲ្យគេក្នុង១ថ្ងៃបងបង្អស់បាន ឈ្នួល៨រ៛៥០ ប្អូនបន្ទាប់បាន៦រ៛៤០ ប្អូនពៅបាន២រ៛៧០ គេសួរថាបុះទាំងអស់គ្នាបានសល់ប្រាក់ប៉ុន្មានរៀលមកផ្ទះ បើក្នុងកំឡុងធ្វើការនោះ១អាទិត្យ ហើយរាចាយទាំងអស់គ្នាអស់៧០រៀល? ។

## ធរណីមាណសាស្ត្រ

អាទិត្យទី ១— សារៀនអំពីផ្ទៃ៤ជ្រុងស្មើ

របៀបបង្រៀន— ចោទសួរអំពីន័យនៃផ្ទៃ៤ជ្រុងស្មើនឹងរកផ្ទៃ៤ជ្រុងស្មើត្រូវធ្វើដូចម្ដេចខ្លះ ។ នឹងគិតរកពាក់កណ្ដាលបរិវេណនឹងរកបរិវេណទាំងមូល ។

ការហាត់គិតដោយបញ្ញានៅលើក្ដារខៀន? សុំឲ្យធ្វើឲ្យបានច្រើន ស្រែមួយរាងបួនជ្រុងស្មើ១ជ្រុងប្រវែង៧ម៉ែត្រ តើពាក់កណ្ដាលបរិវេណស្រែនោះទំហំប៉ុន្មាន ? ។ បរិវេណទាំងមូលទំហំប៉ុន្មាន ? ។ ស្រែនោះទំហំប៉ុន្មានម៉ែត្រក្រឡា ? ។

អ្នកចំការម្នាក់ទិញដី ១ ក្បាលរាង ៤ ជ្រុងស្មើ ១ ជ្រុងប្រវែង៣៦ម៉ែត្រថ្លៃក្នុង១ម៉ែត្រក្រឡា៨៧រ៛៥០តើអ្នកនោះចំណាយអស់ប៉ុន្មាន ? ។

ការហាត់សរសេរ.— គេទិញដីរាងបួនជ្រុងស្មើ១កន្លែង១ជ្រុងប្រវែង

៥៨ម៉ែ៤០ ផ្ទៃក្នុង១ម៉ែត្រក្រឡា៥៩៛៣៥ ហើយគេធ្វើរបងព័ទ្ធជុំវិញគិតទៅក្នុង១ម៉ែត្រអស់ ២៣៛២៥ តើអ្នកនោះចំណាយទាំងអស់ៗប៉ុន្មាន ៗ

អាទិត្យទី២.– សារៀនអំពីផ្ទៃ៤ជ្រុងទ្រវែង

របៀបបង្រៀន– ធ្វើដូចកាលបង្រៀនផ្ទៃ៤ជ្រុងស្មើចោទសួរឲ្យរកន័យពាក់កណ្ដាលបរិវេណបរិវេណទាំងមូល ផ្ទៃក្រឡា ៗ

កាលណាគេដឹងបរិវេណហើយនឹងបណ្ដោយ គេធ្វើដូចម្ដេចនឹងឲ្យឃើញទទឹង ៗ បើដឹងបរិវេណនឹងទទឹងត្រូវធ្វើដូចម្ដេចឲ្យដឹងបណ្ដោយ ៗ បើចង់ឲ្យឃើញបណ្ដោយហើយនឹងផ្ទៃនឹងទទឹងតើត្រូវធ្វើដូចម្ដេច ៗ ធ្វើដូចម្ដេចឲ្យឃើញទទឹងបើដឹងផ្ទៃនឹងបណ្ដោយ ៗ ល ៗ

ការហាត់ដោយបញ្ញានឹងនៅលើក្ដារខ្ពន :

សុំជ្រើសរើសកិច្ចការឲ្យហាត់គិតគូរដូចរបៀបបង្រៀនផ្ទៃ៤ជ្រុងស្មើៗ

បង្រៀនផ្ទៃ ៤ ជ្រុងស្មើ

ការហាត់សរសេរ.– សុំលោកគ្រូជ្រើសរើសកិច្ចការដាក់ឲ្យធ្វើផងចុះ

អាទិត្យទី៣.– សារៀនអំពីត្រីកោណ

របៀបបង្រៀន ចោទសួរដូចកាលបង្រៀនផ្ទៃ ៤ជ្រុងស្មើ ផ្ទៃ ៤ជ្រុងទ្រវែងឲ្យរកន័យរកបរិវេណ ៗ

ត្រីកោណមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? នឹងរកបរិវេណត្រីកោណស្មើជ្រុងតែ២ធ្វើដូចម្តេចខ្លះ ? ត្រីកោណស្មើជ្រុង ? ត្រីកោណឥតស្មើជ្រុង ? ត្រីកោណស្មើជ្រុងទាំង៣ ? ធ្វើដូចម្តេចនឹងរកក្រឡាផ្ទៃត្រីកោណនឹងរកបាត ? នឹងរកកំពស់ ?

ការហាត់ដោយបញ្ហាលើក្ដារឆ្នួនសុំធ្វើដូចមុនៗ

**ការហាត់សរសេរៈ** សុំលោកគ្រូជ្រើសរើសរកកិច្ចការដាក់ឲ្យធ្វើផងចុះ ?

អាទិត្យទី៤.— មេរៀនអំពីវណ្ឌមណ្ឌលនិងផ្ទៃរង្វង់

របៀបបង្រៀន. សុំសាកសួរដូចពីកាលជាន់មុនៗ ឲ្យរកន័យខាតវណ្ឌមណ្ឌល (បន្ទាត់ពុះទីផ្ចិត) របៀបរកប្រវែងវណ្ឌមណ្ឌលរកបន្ទាត់ពុះរកកាំ រកន័យផ្ទៃរង្វង់ការគិតគូរកផ្ទៃរង្វង់ ? រកកាំ ?

អានិកាដ្ឋាន

## វិធីបង្ការរោគ

## គ្រោះថ្នាក់ព្រោះអាភៀន

មនុស្សដែលបណ្ដោយខ្លួនឲ្យញៀនអាភៀន ត្រូវទទួលទុក្ខគ្រប់ប្រភេទៗ អាភៀនធ្វើប្រាជ្ញាឲ្យអាប់ឱនតែកាលណាជក់ជាប់ហើយ ស្បែកកញ្ចៀនឡើងស្វាំងប្រផេះលឿងជ្រួញជ្រីវៗ មនុស្សជក់អាភៀនលែង

ឆ្ងាញ់បាយ បន្តិចម្តង ៗ ថយអាហារ ហើយយូរទៅមានពង់ស្គាំងស្គម ដូចជាអដ្ឋិកសង្ខលិកៈ ៗ ពិការខាងបេះដូងថ្លើមតម្រងទឹកមូត្រ កើតឡើង បណ្តាលឲ្យអវៈយវៈឡើងហើមហើយ ក្នុងទីបំផុតមនុស្សត្រូវតែទទួលមរណភាព ៗ បើគិតខាងប្រាជ្ញាវិញដំបូងសតិស្មារតីឡើងវៀងវៃ សមត្ថភាពចំរើនឡើងប៉ុន្តែនៅបន្ទោះពេលឈប់ជក់សតិធ្លាក់ចុះអ្នកញៀន ទឹកមុខក្រៀមបាត់មាត់ក ធ្វើការអ្វីលែងកើត នៅរង់ចាំតែពេលជក់ ជក់ ទើបមានស្មារតីវៀងវៃឡើងវិញ ៗ ក្នុងទីបំផុតបិត្តធម៌និងចិត្តមេត្តាវិនាសបាត់អស់៖ អ្នកជក់ត្រូវកុហកក៏កុហក ត្រូវលួចក៏លួច ត្រូវសម្លាប់ក៏សម្លាប់ ឲ្យតែបានប្រាក់ទិញជក់ ៗ

ត្រូវកុំចង់ដឹងចង់ជាសេអាភៀនឲ្យសោះ កុំបណ្តោយឲ្យធ្លាក់ទៅជាខ្ញុំអាភៀន ព្រោះតែជក់ហើយច្រើនតែដាច់លែងមិនរួច ៗ

## គ្រោះថ្នាក់ព្រោះស្រា

ស្រាគឺជាថ្នាំពុលមួយ ៗ

អវយវៈអ្នកប្រមឹកទទួលជម្ងឺគ្រប់ទាំងអស់ ៗ ដំបូងរលាកក្រពះ, បេះដូងឡើងប៉ោងហើយមានខ្លាញ់រុំ ៗ សរសៃនាំឈាមក៏តាំងអន់ថយបន្តិចម្តង ៗ សរសៃវិញ្ញាណក៏លែងបំពេញមុខការបានដូចធម្មតា ៗ គ្រឿងប្រដាប់ក្នុងខ្លួនទាំងប៉ុន្មាន ដែលជួយគាំពារជីវិតក៏ធ្លាក់អន់ខ្សោយទាំងអស់ ស្មារតីនឹងបញ្ញាក៏អាប់ឱន ៗ

មនុស្សប្រមឹកបណ្ដាលឲ្យមានទុក្ខដល់គ្រួសារ, ដល់សង្គម; ដល់ជាតិហេតុដូច្នេះយើងមិនត្រូវសេពសុរាទេ ។

បរិច្ឆណាដ្ឋាន

## វិទ្ធស្វាធ្យាយន៍

សំគ្រូសើរើបង្រៀនតាំងពីដើមឆ្នាំមក

អាទិត្យទី ១ អំពីខ្លួនមនុស្ស សាចដុំ

អាទិត្យទី ២ អំពីការ រំលាយអាហារ, ការដកដង្ហើម

អាទិត្យទី ៣ អំពីវិញ្ញាណ ៥ ។

អាទិត្យទី ៤ អំពីច្បាប់ដើរនៅផ្លូវ

## វិធីបង្ការរោគ

អាទិត្យទី ១ វិធីហាត់ប្រាណ

អាទិត្យទី ២ ការសំអាតខ្លួនប្រាណ

អាទិត្យទី ៣ ការថែរក្សាភ្នែក - ត្រចៀក - ធ្មេញនិងសក់

អាទិត្យទី ៤ បញ្ជាក់មេរៀនតាំងពីដើមខែមក សុំមើលក្នុងទស្សនាវដ្ដីខែកញ្ញានិងតុលា ឆ្នាំ ១៩៥០ ១៩៥១

កុមារដ្ឋាន

## វិត្តស្វាព្យាយន៍

### អាទិត្យទី ១ និងទី ២

សុំគ្រូសាបរៀនពីដើមឆ្នាំមកវិញអំពីមេរៀនណាដែលសិស្សមិនទាន់យល់ប្រាកដ ៗ

ដូចជាមេរៀនអំពីឆ្វេងស្ដាំ នឹងច្បាប់ដើរនៅផ្លូវ គួរតែយកមកបញ្ជាក់ជាថ្មីឡើងវិញពីព្រោះសព្វថ្ងៃនេះ ខ្ញុំបានសង្កេតឃើញ ក្មេងច្រើនមិនថាតូចមិនថាធំឡើយ ច្រើនតែធ្វេសប្រហែសស្ដាំ ឆ្វេង បានជាកើតមានគ្រោះថ្នាក់តាមផ្លូវជាញយ ៗ ៗ

សុំគ្រូមើលក្នុងទស្សនាវដ្ដីខែកញ្ញា ឆ្នាំ ១៩៥.
១៩៥១, ប៉ុះ

### អាទិត្យទី ៣ និងទី ៤

អំពីថ្ងៃខែ នឹងរដូវនៅស្រុកខ្មែរ រៀនមើលប្រក្រតីទិន ៗ

សុំមើលក្នុងទស្សនាវដ្ដីខែតុលាឆ្នាំ ១៩៥០-១៩៥១.

# វិធីបង្ការរោគ

សាបព្រៀនពីដើមឆ្នាំមកវិញ ក្នុងខែកញ្ញានឹងតុលា ។
អំពីការសំអាតខ្លួនប្រាណ សំអាតសម្លៀកបំពាក់
ចំណីអាហារនឹងប្រើទឹកឆ្អិន ។

## លោកនីតិ

## សម្រាប់គ្រប់ថ្នាក់

### មេរៀនទី ១ – អំពីរដ្ឋសភា

រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ រដ្ឋសភាមានសិទ្ធិបញ្ចេញមតិតាំងច្បាប់ ។ ច្បាប់ជាសេចក្តីសំដែងឆន្ទះរបស់ប្រជាជាតិ ។ ច្បាប់ត្រូវប្រើទៅលើជនទាំងអស់ បើទោះជាច្បាប់នោះរក្សាការពារក្តី ផ្តន្ទាទោសក្តី បង្ខិតបង្ខំក្តី ។ គណៈរដ្ឋមន្ត្រីជាអ្នកប្រើអំណាចនីតិប្រតិបត្តិក្នុងព្រះរាជអាណាចក្រ ។

អ្នកដែលមានសិទ្ធិផ្តើមគំនិតតែងច្បាប់នោះ គឺព្រះមហាក្សត្រិយ៍គណៈរដ្ឋមន្ត្រីសមាជិកនៃរដ្ឋសភានឹងសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។ ច្បាប់ដែលសមាជិកនៃរដ្ឋសភាផ្តើមគំនិតតែងហៅថាសេចក្តីព្រាងបញ្ញត្តិ ។ ច្បាប់ដែលគណៈរដ្ឋមន្ត្រីផ្តើមគំនិតតែងហៅថាសេចក្តីស្នើបញ្ញត្តិ ។

សមាជិកតាំងឡាយ នៃរដ្ឋសភាជាអ្នកតំណាងរបស់ប្រជាជាតិខ្មែរ ទាំងមូល ពុំមែនត្រឹមតែជាអ្នកតំណាងរបស់ជនដែល ជ្រើសតាំងខ្លួន ប៉ុណ្ណោះទេ ។ សមាជិកនៃរដ្ឋសភាមានចំនួន ៨០ រូប តាមច្បាប់ប្រកាស នៅគ. ស. ១៩៤៧ ដែលស្តីអំពីការ ជ្រើសតាំងអ្នកតំណាងរាស្ត្រ ។

តាមគោលការណ៍ក្នុងចំនួនបុរសខ្មែរ ១០·០០០នាក់ដែលមានអាយុ: ២១ ឆ្នាំឡើងទៅត្រូវមានអ្នកតំណាងមួយរូប ។

អ្នកតំណាងរាស្ត្រត្រូវមានអាយុ: ២៥ ឆ្នាំយ៉ាងតិច ហើយនៅក្នុងតំណែងខ្លួនបានត្រឹមតែ ៤ ឆ្នាំទេ ។ មុននឹងចូលកាន់តំណែងសមាជិកនៃរដ្ឋសភាតាំងសច្ចាប្រណិធានក្នុងទីប្រជុំចំពោះព្រះ ភក្ត្រព្រះមហាក្សត្រិយ៍ ថាមានចិត្តស្មោះត្រង់ចំពោះព្រះភក្ត្រព្រះមហាក្សត្រិយ៍ថា ានចិត្តស្មោះត្រង់ ចំពោះព្រះមហាក្សត្រិយ៍ ហើយនឹងរដ្ឋធម្មនុញ្ញ ។

អ្នកតំណាងរាស្ត្រមិនអាចត្រូវចោទប្រកាន់រកខ្លួនចាប់ខ្លួនឃុំឃាំងឬជំនុំជំរះក្នុងពេលដែលថិតក្នុងសមាជិកភាពទេ វៀរលែងតែអ្នកតំណាងរាស្ត្រនោះបានប្រព្រឹត្តបទល្មើសដែលបានទាន់ឃើញជាក់ស្តែង ។

រដ្ឋសភាមានសម័យប្រជុំសាមញ្ញយ៉ាងតិចបីខែ ។ ក្នុងសម័យប្រជុំសាមញ្ញពីរនេះសម័យប្រជុំមួយ ៗ មានកំណត់យ៉ាងតិចបីខែ ។ ក្នុងសម័យប្រជុំសាមញ្ញពីរនេះសម័យប្រជុំមួយត្រូវចាប់ផ្តើមក្នុងខែកញ្ញា ។ ព្រះមហាក្សត្រិយ៍ទ្រង់ត្រាស់ហៅរដ្ឋសភាប្រជុំជាសម័យប្រជុំសាមញ្ញ ។

ជាក្រុមអភិបាលរដ្ឋសភាជាអ្នក ហៅសមាជិកប្រជុំជាសម័យប្រជុំវិសាមញ្ញដោយបានទទួលព្រះរាជបញ្ជាក្ដី ដោយសេចក្ដីណែនាំនៃគណៈរដ្ឋមន្ត្រីក្ដី ឬដោយសេចក្ដីសុំ របស់ភាគមួយក្នុងភាគបី (១/៣) យ៉ាងតិចនៃចំនួនអ្នកតំណាងរាស្ត្រទាំងពួងក្ដី ។

របៀបវារៈនៃសម័យប្រជុំ វិសាមញ្ញនេះត្រូវផ្សាយដល់មហាជនព្រមជាមួយនឹងថ្ងៃណាត់ប្រជុំ ។ សេចក្ដីគត់ហេតុនៃសម័យប្រជុំនោះត្រូវចុះផ្សាយក្នុងរាជកិច្ចផង ។

## មេរៀនទី ២ អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ

ក្រុមប្រឹក្សាព្រះរាជអាណាចក្រនឹងរដ្ឋសភារួមគ្នាហៅថាសភា ។ ក្រុមប្រឹក្សាព្រះរាជអាណាចក្រគ្មានសិទ្ធិបញ្ចេញមតិតាំងច្បាប់ទេ ហើយកាន់អំណាចតិចជាងរដ្ឋសភាផង ។ គណៈរដ្ឋមន្ត្រីមិនទទួលខុសត្រូវចំពោះក្រុមប្រឹក្សាព្រះរាជអាណាចក្រទេ ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រមានសមាជិក ២៤ រូប ។ សមាជិកខ្លះត្រូវចាត់តាំង ខ្លះត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកល ។ សមាជិកទាំងនោះត្រូវមានអាយុ ៤០ ឆ្នាំយ៉ាងតិច ។ អាណត្តិនៃទីប្រឹក្សាព្រះរាជអាណាចក្រមានកំណត់បួនឆ្នាំ ហើយទីប្រឹក្សាព្រះរាជអាណាចក្រ ត្រូវហៅប្រជុំ ហើយត្រូវប្រជុំក្នុងពេលជាមួយគ្នានឹងរដ្ឋសភា ។

ក្នុងមួយឆ្នាំ ៗ ក្រុមប្រឹក្សាព្រះរាជអាណាចក្រជ្រើសតាំងប៊ុរ៉ូនៃគណៈកម្មការនានារបស់ខ្លួនដូចរដ្ឋសភាដែរ ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្របានពិនិត្យហើយឲ្យយោបល់អំពីសេចក្ដីព្រាងនឹងសេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមមួយលើកបំបូនរួចហើយ ព្រមទាំងអំពីបញ្ហាទាំងពួងដែលរដ្ឋាភិបាលបានដាក់ឲ្យពិនិត្យ ។

អំពីសេចក្ដីព្រាងច្បាប់នឹងសេចក្ដីស្នើច្បាប់ ហើយនឹងអំពីច្បាប់ថវិកា ក្រុមប្រឹក្សាព្រះរាជអាណាចក្រត្រូវឲ្យយោបល់កំណត់មួយខែយ៉ាងយូរ ។ បើជាការកំណត់វេលានោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្របានឲ្យយោបល់យល់ព្រមឬពុំបានឲ្យយោបល់សោះក្នុងវេលាដែលមានកំណត់ទុកហើយនោះច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមហើយនោះ ត្រូវប្រកាសឲ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។ បើជាការប្រញាប់ កំណត់វេលានោះត្រូវបន្ថយមកនៅត្រឹមតែពីរថ្ងៃ

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ សូមកែសម្រួលសេចក្ដីព្រាងឬសេចក្ដីស្នើច្បាប់ នោះរដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទី ២ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្របដិសេធសេចក្ដីព្រាងឬសេចក្ដីស្នើច្បាប់នោះ រដ្ឋសភាមិនអាចយកមកពិចារណាលើកទី ២ មុនកំណត់ពេលមួយខែទេ ។

ការពិនិត្យសេចក្ដីឬសេចក្ដីស្នើច្បាប់ជាលើកទី ២ នេះរដ្ឋសភាត្រូវបញ្ចេញមតិ ដោយវិធីបោះឆ្នោតបំហយកតាមភាគច្រើនដោយដាច់ខាតនៃសមាជិករដ្ឋសភា ។ សេចក្ដីព្រាងឬសេចក្ដីស្នើច្បាប់ណាដែលបានធ្វើសម្រេចដូចខាងលើនេះហើយ ត្រូវប្រកាសឲ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។

## អំពីរបៀបជ្រើសតាំងអ្នកតំណាងរាស្ត្រ

ក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ បណ្ដាជនទាំងអស់ដួយចាត់ចែងការគ្រប់គ្រងប្រទេសខ្លួន ប៉ុន្តែមិនមែនចាត់ចែងដោយបំពោះទេ គឺ **តាមរយៈនៃអ្នកតំណាងខ្លួន** ។

ក្នុងសម័យបោះឆ្នោតមានបេក្ខជនជាច្រើន ឈរឈ្មោះឲ្យគេជ្រើសតាំងជាអ្នកតំណាងរាស្ត្រ ។ បុរសដែលមានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រទាំងឡាយក៏បោះឆ្នោតឲ្យឈ្មោះ បេក្ខជនណាមួយដែលខ្លួនគាប់ចិត្តខ្លួន ។ បោះឆ្នោតគឺយល់ព្រមទទួលយកឬមិនយល់ព្រមទទួលយកបេក្ខជនណាមួយធ្វើជាតំណាងខ្លួនៗ អធិបតេយ្យនៃបណ្ដាជនទាំងឡាយនឹងអាចប្រព្រឹត្តទៅបានដោយសារជ្រើសតាំងអ្នកតំណាងនេះ ដ្បិតអ្នកតំណាងនេះហើយដែលជាអ្នកសម្រេចការផ្សេងៗ នឹងចាត់ចែងកិច្ចការនានាក្នុងការគ្រប់គ្រងប្រទេស ព្រមទាំងជាអ្នកតែងច្បាប់ក្នុងនាមបណ្ដាជនផង ។ ការបោះឆ្នោតជាការមួយសំខាន់ណាស់ចំពោះប្រទេស ពីព្រោះជោគវាសនារបស់ប្រទេសចិតនៅក្នុងកណ្ដាប់ដៃនៃអ្នកតំណាង

រាស្ត្រ។ រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា បើកឲ្យប្រុសខ្មែរទាំងអស់មានសិទ្ធិជ្រើសតាំងអ្នកតំណាងដូច្នេះបណ្ដាជនទាំងឡាយ ត្រូវប្រើសិទ្ធិនេះឲ្យពេញលេញ មិនបញ្ចេញមតិជ្រើសតាំងគឺលះបង់ចោលអំណាចដែលខ្លួនមាន ដើម្បីជួយជ្រោមជ្រែងរបៀបចាត់ចែងការគ្រប់គ្រងប្រទេស ។ ជ្រើសតាំងដោយទុច្ចរិតគឺច្រានប្រទេសទាំងមូលទៅក្នុងភយន្តរាយផ្សេងៗ ។

ហេតុនេះពលរដ្ឋម្នាក់ៗមានករណីយកិច្ចនឹងជ្រើសតាំងអ្នកតំណាងខ្លួនឲ្យត្រឹមត្រូវគឺថា ជ្រើសតាំងដោយឥតទាក់ទិននឹងលាភប្ដូរផលប្រយោជន៍ដទៃ ដោយឯកច្ឆន្ទចិត្តឥតមានអ្នកឯណាបង្ខិតបង្ខំ គឺជ្រើសតាំងតាមសម្បជញ្ញៈ ខ្លួន ។

ត្រូវបោះឆ្នោតឲ្យបេក្ខជនណាដែលយើងជឿជាក់ថា មានសម្បទានឹងធ្វើការឲ្យប្រទេសបាន ។

## មេសូត្រត្រូវចាំមាត់

( សម្រាប់គ្រប់ថ្នាក់ )

### ១-- គុណសិស្សល្អ

ចេះតែឧស្សាហ៍ ប្រឹងធ្វើកិច្ចការ ចាំចប់ឥតសល់ នៅក្នុងថ្នាក់រៀន
ស្ដាប់គ្រូពន្យល់ ឥតមានអំពល់ ពីកិច្ចដទៃ ។ គោរពកោតខ្លាច លុះដោយ
អំណាច នៃគ្រូពោលស្ដី ចិត្តធ្ងន់ស្លូតត្រង់នឹងក្មេងដទៃ កូនសិស្សប្រុសស្រី
យកដម្រាប់តែវ ។

ពាក្យពន្យល់-អំពល់ = ធ្វើឲ្យខកខាន ។

ពោល = និយាយ ស្តី, ថា ។

កិច្ច = ការដែលត្រូវធ្វើ ។

## ២- កូនប្រុសល្អ

ចៅឃុតសប្បាយ ដោយខំខ្វល់ខ្វាយ ធ្វើកិច្ចសព្វគ្រប់ រៀននៅសាលា
កាលណាពេលឈប់ ធ្វើការឈ្នួលគ្រប់ យកប្រាក់ខែ-ថ្ងៃ ។ ចិញ្ចឹមមាតា
មាតាបិតា ឥតមានត្អូញត្អែរ លុះវាឃុតធំ ល្បីឈ្មោះមានកេរ្តិ៍ បានធ្វើជា
មេ មន្ត្រីរាជការ ។ ពេលលោកមានបុណ្យ ធ្វើកិច្ចសងគុណ មាតាបិតា
លោកឃុតកតញ្ញូ សុភាពរាបសា គួរសិស្សគ្រប់គ្នា យកដម្រាប់តាម ។

ពាក្យពន្យ - ខ្វល់ខ្វាយ ខ្នះខ្នែង ។

កិច្ច = ការដែលត្រូវធ្វើ ។

ត្អូញត្អែរ – ត្អូញហើយត្អូញទៀតបែបប្រែ ។

កេរ្តិ៍ = ( ម.ប. កេ) សេចក្តីសរសើរ ។

## ៣- សេចក្តីព្យាយាម

ទឹកស្រក់លើថ្ម យូរៗទៅក៏ ធ្លុះថ្មនោះបាន កាឈើតិចៗ ដាច់ជា
ផ្ទាំងផ្ទាន កណ្ដៀរធ្វើបាន ដំបូកយ៉ាងធំ ។ បក្សីពាំស្មៅ ម្ដងមួយទងទៅ
ធ្វើជាទីទំ សំរេចបានដោយ ព្យាយាមយ៉ាងមាំ បានទ្រព្យស្តុកស្តម្ភ

ព្រោះខំព្យាយាម ៗ បើយើងពលគ្នា បង្កទ្រព្យា សំរេចទៅបាន សេចក្តីប្រឹងប្រែង ខ្នះខ្នែងព្យាយាម ទើបទ្រព្យកើតតាម ប្រាថ្នានៃយើង

ពាក្យពន្យល់បក្សី – សត្វមានស្លាប ៗ

ស្តុកស្តម្ភ ( មច ស្តំ ) មាំមួន

ច្រើន ៗ បង្ក ធ្វើឲ្យកើតឡើង ៗ

## ៤– មនុស្សមានឫទ្ធានុភាពជាងសត្វ

អ្នកស្រែវាយក្របី វាស្ពឹកទុក្ខវេទនា
ស្រាប់តែមានសត្វខ្លា និយាយថាបងក្របី ៗ
ជាតិមនុស្សតូចជាងអ្នក ឲ្យវាយបានព្រោះហេតុអ្វី
ពេលនោះសត្វក្របី ឆ្លើយថាមនុស្សមានបញ្ញា ៗ
សត្វខ្លាក៏រាកបែរ សួរអ្នកស្រែទុកឯណា
អ្នកស្រែក៏ឆ្លើយថា បញ្ញាអញទុកឯផ្ទះ ៗ
ចូរអ្នកទៅយកមើល ខ្ញុំចង់ឃើញឲ្យបានច្បាស់
ឆ្លើយថាបើទៅផ្ទះ មុខជាឯងនាំក្របី ៗ
បើចង់ឃើញបញ្ញា អញចងអាបានឬអ្វី
សត្វខ្លាល្ងង់អព្រើយ ក៏បើកដៃឲ្យមនុស្សចង ៗ
អ្នកស្រែក៏ចងខ្លា គេខ្ទួនវាច្រើនចំណង ៗ
រួចហើយវាយសំពង ប្រាប់ថាហ្នឹងបញ្ញាមនុស្ស ៗ

ពាក្យបន្សល់ អប្រិយ មិនគាប់ចិត្ត ។

ចំណង់ កំនួចដែលចង់កួចក្ជាប់

គ្នា ។ ឫទ្ធានុភាព ដោយអំណាចរិទ្ធ ។

## ៥- ប្រយោជន៍នៃវិជ្ជា

វិជ្ជាទ្រព្យប្រសើរ　　វិជ្ជាធ្វើមនុស្សថោកទាប
ឲ្យបានសួស្ដីភាព　　វិជ្ជាប្រៀបដូចស្នេហ៍មុខ ។
វិជ្ជាមានវិន័យ　　ដឹងដម្លៃកើតទ្រព្យសុខ
វិជ្ជារួបបាកទុក្ខ　　វិជ្ជាចោរលួចពុំបាន ។
វិជ្ជានោះមានពីរ　　ចូរប្រុសស្រីរៀនកំខាន
សិល្បវិជ្ជារៀនទៅបាន　　តាំងសើបលេងគ្មុកកំម្លែង ។
ឯសាស្ត្រវិជ្ជាវិញ　　ត្រូវស្រឡាញ់គោរពក្រែង
កន្ទីសព្វកន្ទែង　　ពុំដែលចោលទីណាឡើយ ។

ពាក្យពន្យល់ វិជ្ជា ចំណេះ ។ សួស្ដី សេចក្ដីត្រេកអរ

ស្នេហ៍ សេចក្ដីស្រឡាញ់

វិន័យ = ច្បាប់ ។ សិល្បវិជ្ជា

ការចេះសិល្បសាស្ត្រ ។ សាស្ត្រាវិជ្ជា = គម្ពី

គ្រប់វិជ្ជាផ្សេង ៗ

P.-P. Imp. KHMERE, Tous droits réservés Tirage 5,581 ex.